# របាយការណ៍លទ្ធផល
# កិច្ចពិភាក្សាក្នុងអង្គសន្និសីទថ្នាក់តំបន់ និងថ្នាក់ជាតិលើកទី១៣ ស្តីពីអភិបាលកិច្ចដីធ្លី និងធនធានធម្មជាតិ ឆ្នាំ២០២០

## ខេត្តសៀមរាប បាត់ដំបង កំពត និង រាជធានីភ្នំពេញ

## សាវតា

នៅឆ្នាំ២០២០ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា សហការជាមួយអង្គការដៃគូ និងអង្គការសមាជិកបណ្តាញសិទ្ធិដីធ្លី និងលំនៅឋាន បណ្តាញសិទ្ធិជនជាតិដើមភាគតិច និងព្រៃឈើ និងបណ្តាញសង្គមស៊ីវិលវេជបូក បានរៀបចំសន្និសីទថ្នាក់តំបន់ និងថ្នាក់ជាតិ ក្រោមប្រធានបទ ស្តីពីអភិបាលកិច្ចដីធ្លី និងធនធានធម្មជាតិ សរុបចំនួន៤តំបន់ផ្សេងៗគ្នា ដែលមានអ្នកចូលរួមសរុបចំនួន៧៣៩នាក់ (ស្ត្រី១៤៦នាក់) រួមមានតំណាងរដ្ឋសភាជាតិ តំណាងក្រសួង និងមន្ទីរពាក់ព័ន្ធ ក្រុមហ៊ុនឯកជន អ្នកសិក្សាស្រាវជ្រាវ និងតំណាងប្រជាពលរដ្ឋដែលមានវិវាទដីធ្លី សហគមន៍ជនជាតិដើមភាគតិច សហគមន៍នេសាទ សហគមន៍ព្រៃឈើ និងសហគមន៍តំបន់ការពារធម្មជាតិ និងតំណាងអង្គការមិនមែនរដ្ឋាភិបាល អញ្ជើញមកពី២០ រាជធានីខេត្ត នៃព្រះរាជាណាចក្រកម្ពុជា រួមមាន រាជធានីភ្នំពេញ ខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង ប៉ៃលិន បន្ទាយមានជ័យ សៀមរាប កំពង់ធំ ឧត្តរមានជ័យ ព្រះវិហារ ស្ទឹងត្រែង រតនគីរី មណ្ឌលគីរី កំពង់ស្ពឺ ព្រៃវែង ស្វាយរៀង តាកែវ កំពត ព្រះសីហនុ និងកោះកុង។

ក្នុងនោះ មានសន្និសីទថ្នាក់តំបន់ចំនួន៣ ដែលបានការរៀបចំ ទី១. នៅខេត្តសៀមរាប ថ្ងៃទី១០-១១ ខែសីហា ឆ្នាំ២០២០ មានអ្នកចូលរួមសរុប២៥៩នាក់ (ស្ត្រី៤០នាក់) ទី២. នៅខេត្តបាត់ដំបង ថ្ងៃទី០៩-១០ ខែកញ្ញា ឆ្នាំ២០២០ មានអ្នកចូលរួមសរុប១៣៧នាក់ (ស្ត្រី៣១នាក់) ទី៣. នៅខេត្តកំពត ថ្ងៃទី០១-០២ ខែតុលា ឆ្នាំ២០២០ មានអ្នកចូលរួមសរុប១៥៧នាក់ (ស្ត្រី៣៧នាក់) រីឯសន្និសីទថ្នាក់ជាតិលើកទី១៣ នៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២០ មានអ្នកចូលរួមសរុប១៨៦នាក់(ស្ត្រី៣៨នាក់)។ គោលបំណងនៃការរៀបចំសន្និសីទទាំងថ្នាក់តំបន់ និងថ្នាក់ជាតិគឺដើម្បី ផ្តល់ឱកាសដល់តំណាងសមាជិកសហគមន៍ អង្គការសង្គមស៊ីវិល តំណាងរដ្ឋសភា រាជរដ្ឋាភិបាលថ្នាក់ជាតិ និងក្រោមជាតិ វិស័យឯកជន និងអ្នកសិក្សាស្រាវជ្រាវបានជួបជុំគ្នាដើម្បីពិភាក្សានិងលើកឡើងនូវសមិទ្ធផលការងារសំខាន់ៗរបស់រាជរដ្ឋាភិបាល បញ្ហាប្រឈម និងមតិយោបល់ប្រកបដោយការស្ថាបនា សម្រាប់ជាធាតុ

ចូលដ៏សំខាន់ជូនតំណាងរាជរដ្ឋាភិបាល រដ្ឋសភា និងស្ថាប័នពាក់ព័ន្ធផ្សេងទៀត ដើម្បីពិចារណាដោះស្រាយ និងបញ្ចូលក្នុងច្បាប់ គោលនយោបាយ និងផែនការអនុវត្តរបស់ជាតិ ឱ្យកាន់តែមានភាពល្អប្រសើរឡើងថែមទៀត។

ឆ្លៀតក្នុងឱកាសនេះ តាងនាមឱ្យអង្គការមិនមែនរដ្ឋាភិបាល និងតំណាងសហគមន៍ ដែលបានចូលរួមសហការរៀបចំសន្និសីទទាំងនេះ ខ្ញុំសូមធ្វើរបាយការណ៍លទ្ធផលរួមនៃកិច្ចពិភាក្សាក្នុងអង្គសន្និសីទ ស្តីពីអភិបាលកិច្ចដីធ្លី និងធនធានធម្មជាតិ និងគោរពជូនរាជរដ្ឋាភិបាល (ថ្នាក់ជាតិ និងក្រោមជាតិ) រដ្ឋសភាជាតិ ព្រឹទ្ធសភា និងស្ថាប័នពាក់ព័ន្ធនានា ដើម្បីពិនិត្យពិចារណា និងចំណាត់ការដោះស្រាយ ដែលមានខ្លឹមសារដូចខាងក្រោម៖

## ១. ប្រធានបទស្តីពីសិទ្ធិដីធ្លី និងលំនៅឋាន

### ១.១ សមិទ្ធផលសំខាន់ៗរបស់អភិបាលកិច្ចដីធ្លី

តាមលទ្ធផលពិគ្រោះយោបល់នៃអង្គសន្និសីទថ្នាក់ជាតិ និងថ្នាក់តំបន់បានបង្ហាញថា ក្នុងឆ្នាំ២០១៩ និងឆ្នាំ២០២០នេះ រាជរដ្ឋាភិបាលកម្ពុជាបានខិតខំដោះស្រាយបញ្ហាដីធ្លី និងធនធានធម្មជាតិ ទទួលបានលទ្ធផលល្អប្រសើរគួរឱ្យកត់សម្គាល់ តាមរយៈការធ្វើវិសោធនកម្មច្បាប់ពាក់ព័ន្ធមួយចំនួនដូចជា ច្បាប់ភូមិបាល ឆ្នាំ២០០១ ច្បាប់ស្តីពីជលផល ច្បាប់ស្តីពីព្រៃឈើ និងច្បាប់ស្តីពីតំបន់ការពារធម្មជាតិ និងការពង្រឹងការអនុវត្តច្បាប់ ដូចជា ការធ្វើកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ ការដោះស្រាយវិវាទដីធ្លី ការចុះបញ្ជីដីធ្លី ការបង្ក្រាបបទល្មើសទន្ទ្រានយកដីសាធារណៈរបស់រដ្ឋ និងបទល្មើសជួញដូរឈើខុសច្បាប់ និងដំណោះស្រាយអភិវឌ្ឍន៍នៅនឹងកន្លែងជូនសហគមន៍ក្រីក្រទីក្រុង។ សមិទ្ធផលជាក់ស្តែង ដែលរាជរដ្ឋាភិបាលកម្ពុជា ថ្នាក់ជាតិ និងក្រោមជាតិ សម្រេចបាន រួមមាន៖

- ការរៀបចំបទដ្ឋានគតិយុត្តិពាក់ព័ន្ធនឹងដីធ្លី និងលំនៅឋាន ដូចជា ការធ្វើវិសោធនកម្មច្បាប់ភូមិបាលឆ្នាំ២០០១ ការរៀបចំធ្វើច្បាប់ ស្តីពីលំនៅឋាន សេចក្តីព្រាងក្របខណ្ឌយុទ្ធសាស្ត្រជាតិ ស្តីពីការអភិវឌ្ឍក្រុង សេចក្តីសម្រេចលេខ ០៣៩ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២០ ស្តីពីការបង្កើតគណៈកម្មការគាំទ្រចុះបញ្ជីដីរដ្ឋ ដីកម្មសិទ្ធិឯកជន ដីសមូហភាពជនជាតិដើមភាគតិច ដោះស្រាយវិវាទដីធ្លី និងរៀបចំផែនការប្រើប្រាស់ដីនៅខេត្តមណ្ឌលគិរី។
- យោងតាមរបាយកាណ៍បូកសរុបការងាររយៈពេល៩ខែ ឆ្នាំ២០២០ លេខ០៥២ ដនស/អរប/នរប/របា ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២០ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ លទ្ធផលនៃការចុះបញ្ជីដីធ្លីសម្រេចបានចេញប័ណ្ណកម្មសិទ្ធិចំនួន ២៦៩១២០ប័ណ្ណ និងចែកដល់ដៃប្រជាពលរដ្ឋចំនួន ២៧០៨១០ប័ណ្ណ។ ការដោះស្រាយវិវាទដីធ្លីដោយយន្តការគណៈកម្មការសុរិយោដីរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដោះស្រាយបញ្ចប់នីតិវិធីចំនួន១៦៧ករណី (បញ្ចប់ជាស្ថាពរ ៧៦ករណី) ក្នុងចំណោមបណ្តឹងទទួលបានចំនួន១៨០ករណី។
- រដ្ឋបាល**ខេត្តកំពត** លេខ ៤៨៩/២០ សជណ៖ ជូនដំណឹងប្រជាពលរដ្ឋពីការទទួលពាក្យលើការកាន់កាប់ដីអាស្រ័យផលជាក់ស្តែងក្នុងឧទ្យានជាតិព្រះមុនីវង្ស បូកគោ ខេត្តកំពត ។
- រដ្ឋបាល**ខេត្តព្រះសីហនុ** លេខ ៣១២/២០ សជណ៖ ជូនដំណឹងប្រជាពលរដ្ឋពីការទទួលពាក្យលើការកាន់កាប់ដីអាស្រ័យផលជាក់ស្តែងយូរឆ្នាំនៅលើទីតាំងដី ក្នុងដែនសមត្ថកិច្ចគ្រប់គ្រងរបស់ក្រសួង

កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្ថិតក្នុងភូមិសាស្ត្រខេត្តព្រះសីហនុ។ ក្នុងឆ្នាំ២០២០ អាជ្ញាធរខេត្តព្រះសីហនុបានចាត់វិធានការទប់ស្កាត់បញ្ហាទំនាស់ដីធ្លី ដោយចាប់យកគ្រឿងចក្រចំនួន២គ្រឿង ដែលឈូសឆាយដីទំនាស់ មកយករក្សាទុកនៅសាលាស្រុកស្ទឹងហាវ ។

- រដ្ឋបាល**ខេត្តបាត់ដំបង** បានគាំពារសហគមន៍ក្រីក្រនៅក្នុងក្រុងបាត់ដំបង ទទួលបានគម្រោងផ្លូវបេតុង តបណ្ដាញអគ្គិសនី បណ្ដាញទឹកស្អាត ដោយមានបដិភាគសហគមន៍ និងរដ្ឋាភិបាល។ ដីលំនៅឋានប្រជាពលរដ្ឋ នៅក្នុងឃុំបឹង៥ ស្រុកបវេល ប្រមាណ៧០% ទទួលបានចុះបញ្ជីក្បាលដី និងប្លង់កម្មសិទ្ធ ។
- គណៈកម្មការ**ខេត្តកំពង់ឆ្នាំង** បានសម្របសម្រួលដោះស្រាយវិវាទដីធ្លីនៅក្នុងភូមិជរ ភូមិប្រស្នឹប ឃុំប្រស្នឹប ស្រុករលាប្អៀរ ហើយប្រជាពលរដ្ឋចំនួន២៥គ្រួសារបានទទួលប្រាក់សំណង ។
- អាជ្ញាធរ**រាជធានីភ្នំពេញ** បានផ្ដល់អត្រានុកូលដ្ឋាន និងលំនៅឋានសមរម្យជូនគ្រួសារសហគមន៍ ព្រមទាំងរៀបចំហេដ្ឋារចនាសម្ព័ន្ធ សេវាកម្មមូលដ្ឋាន នៅក្នុងសហគមន៍ក្រីក្រទីក្រុងមួយចំនួន ។
- រដ្ឋបាល**ខេត្តសៀមរាប** បានបញ្ចូលផែនការ ពិភាក្សារកដំណោះស្រាយដីធ្លីលំនៅឋានដល់សហគមន៍ក្រក្រីនៅក្នុងខេត្តសៀមរាប ។ ប្រជាពលរដ្ឋរស់នៅដីវត្តបូព៌ ទទួលបានការដោះដូរដីឡូត៍ទំហំ៧មx១៥ម នៅភូមិវាល សង្កាត់សំបួរ ក្រុងសៀមរាប ប្រហែល៣គមពីទីតាំងចាស់ ។

## ១.២ បញ្ហាប្រឈម

- **ភាពចង្អៀតនៃការចូលរួមរបស់តួអង្គជាប់ពាក់ព័ន្ធក្នុងដំណើរការវិសោធនកម្មច្បាប់ភូមិបាលឆ្នាំ២០០១:** ការរៀបចំធ្វើវិសោធនកម្មច្បាប់ភូមិបាលឆ្នាំ២០០១ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ហាក់មិនទាន់បានផ្សព្វផ្សាយជាសាធារណៈ ឬ ផ្លូវការ និងបើកឱកាសទូលំទូលាយដល់អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធផ្សេងៗទៀត បានចូលរួមដំណើរការធ្វើវិសោធនកម្មច្បាប់នេះ ដើម្បីសហការរៀបចំកិច្ចពិគ្រោះយោបល់ ប្រមូលធាតុចូលពីគ្រប់អ្នកពាក់ព័ន្ធ ដើម្បីឱ្យច្បាប់នេះកាន់តែមានភាពល្អប្រសើរឡើងថែមទៀត។

- **បញ្ហាកង្វះបទដ្ឋានគតិយុត្ត ឬ គោលនយោបាយជាតិស្តីពីសំណងសមរម្យ និងយុត្តិធម៌ សម្រាប់អនុវត្តគ្រប់គម្រោងអភិវឌ្ឍន៍:** ប្រទេសកម្ពុជាមិនទាន់មានគោលនយោបាយជាតិ ឬ គោលការណ៍ណែនាំរួមស្តីពីសំណងសមរម្យ និងយុត្តិធម៌ សម្រាប់ដោះស្រាយផលប៉ះពាល់នៃគម្រោងអភិវឌ្ឍន៍នៅកម្ពុជា។ ការអនុវត្តជាក់ស្តែង រាជរដ្ឋាភិបាលកម្ពុជា បានរៀបចំគោលនយោបាយស្តីពីសំណងដោះស្រាយប៉ះពាល់នៃគម្រោងអភិវឌ្ឍន៍ដាច់ដោយឡែកផ្សេងគ្នា និងមានស្តង់ដារខុសៗគ្នា ការចូលរួមពិគ្រោះយោបល់ជាសាធារណៈមិនទាន់ពេញលេញ និងមិនមានយន្តការបណ្ដឹងតវ៉ា ដើម្បីធានានូវគោលការណ៍ឆ្ពោះទៅរកយុត្តិធម៌ លើកលែងតែគម្រោងអភិវឌ្ឍន៍របស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ធនាគារពិភពលោក (WB) និងគម្រោងអភិវឌ្ឍន៍របស់JICA។

- **បញ្ហាសហគមន៍ក្រីក្រ ដែលតាំងទីលំនៅ ក្នុងតំបន់មិនរៀបរយ៖** សហគមន៍ក្រីក្រភាគច្រើនដែលតាំងទីលំនៅ ក្នុងតំបន់មិនរៀបរយ កំពុងប្រឈមនឹងបញ្ហាសុវត្ថិភាពដីធ្លី និងផ្ទះសម្បែង សន្តិសុខ សុខភាព អនាម័យ (បរិស្ថាន កខ្វក់ ទឹកលិច) ខ្វះការសិក្សាអប់រំ ខ្វះ ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ក្នុងសហគមន៍ ខ្វះវិជ្ជាជីវៈជំនាញ និងមុខរបរចិញ្ចឹមជីវិត ការចំណាយខ្ពស់លើតម្លៃអគ្គិសនី-ទឹកស្អាត ដោយសារតភ្ជាប់ពីបុគ្គលឯកជន។ សហគមន៍ក្រីក្រមួយចំនួនមិនទាន់បានធ្វើបច្ចុប្បន្នភាព សិក្សាឈ្វេងយល់លម្អិតអំពីប្រជាសាស្ត្រ ទីតាំងភូមិសាស្ត្រ និងតម្រូវការរបស់ពួកគាត់ ដើម្បីរៀបចំផែនការដោះស្រាយឱ្យមានប្រសិទ្ធភាព។

- **ការដោះស្រាយសំណងផលប៉ះពាល់នៃគម្រោងអភិវឌ្ឍន៍ និងការអភិវឌ្ឍតំបន់តាំងទីលំនៅឋានថ្មី៖** ដើម្បីអភិវឌ្ឍសេដ្ឋកិច្ចប្រទេសជាតិ រាជរដ្ឋាភិបាលកម្ពុជា បានផ្តល់សម្បទានដី សម្រាប់គម្រោងអភិវឌ្ឍន៍ តំបន់សេដ្ឋកិច្ចពិសេស តំបន់ពាណិជ្ជកម្ម និងទេសចរណ៍ខ្នាតអន្តរជាតិ ដល់ក្រុមហ៊ុនឯកជនមួយចំនួន ដូចជា ក្រុមហ៊ុន Union Development Group Co.,Ltd នៅខេត្តកោះកុង ក្រុមហ៊ុន OCICនៅជ្រោយចង្វារ រាជធានីភ្នំពេញ គម្រោងអភិវឌ្ឍន៍ទំនប់វារីអគ្គីសនីសេសានក្រោម២ នៅខេត្តស្ទឹងត្រែង និងគម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ ប្រព័ន្ធធារាសាស្ត្រ ដូចជា ទំនប់ទឹករក្សា នៅស្រុករវៀង ខេត្តព្រះវិហារ ។ល។ គម្រោងធំៗទាំងអស់នេះសុទ្ធតែ ផ្តល់ផលប៉ះពាល់ដល់សង្គម។ ជាក់ស្តែង ប្រជាពលរដ្ឋដែលទទួលរងផលប៉ះពាល់ កំពុងបន្តរស់នៅលើដីតំបន់រដ្ឋបាលភូមិ ឃុំ និងស្រុក ដែលបានចុះបញ្ជីត្រឹមត្រូវ និងទទួលស្គាល់ដោយក្រសួងមហាផ្ទៃ គឺជាម្ចាស់ដីភោគៈត្រឹមត្រូវតាមច្បាប់ពិតប្រាកដ ត្រូវបានដកហូតសិទ្ធិ និងយកដីធ្លីរបស់ពួកគាត់ប្រគល់ឱ្យទៅក្រុមហ៊ុនអភិវឌ្ឍន៍តាមផែនការរបស់ក្រុមហ៊ុន ដោយផ្តល់សំណងទាប និងតម្រូវឱ្យពួកគាត់ផ្លាស់ប្តូរលំនៅឋានទៅទីតាំងថ្មី ទាំងមិនស្ម័គ្រចិត្ត។ យោងតាមរបាយការណ៍សិក្សាស្រាវជ្រាវរបស់អង្គការសង្គមស៊ីវិល បានបង្ហាញថា ការដោះស្រាយផលប៉ះពាល់មិនទាន់មានតម្លាភាព មិនទទួលបានសំណងសមរម្យ ខ្វះការគោរពគោលនយោបាយស្បែកខ្លា (កាត់ឆ្វៀលដីកាន់កាប់ជាក់ស្តែងជូនប្រជាពលរដ្ឋ) ចំណែកការអនុវត្តគម្រោងផ្លាស់ប្តូរលំនៅឋានថ្មី ការរៀបចំផែនការមេស្តីពីការតាំងទីលំនៅថ្មី និងការអនុវត្តមិនទាន់ល្អ ជាហេតុធ្វើឱ្យអាជ្ញាធរមានសមត្ថកិច្ចមិនអាចគោរពបានតាមកិច្ចសន្យាជាមួយប្រជាពលរដ្ឋទទួលរងផលប៉ះពាល់ទាំងនោះថា «ការអភិវឌ្ឍនៅតំបន់តាំងទីលំនៅថ្មីមិនឱ្យទាបជាងស្តង់ដារដើម»។ ក្នុងការអនុវត្តជាក់ស្តែង ប្រជាពលរដ្ឋត្រូវបានផ្លាស់ប្តូរទៅរស់នៅតំបន់ថ្មីទាំងមិនទាន់រៀបចំរួចរាល់ជាស្ថាពរ។ ពួកគាត់បានជួបបញ្ហាជាច្រើនដូចជា សំណង់ផ្ទះពុំមានគុណភាព ខ្វះហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ប្រព័ន្ធលូ បង្គន់អនាម័យ ទឹកស្អាត ភ្លើង មណ្ឌលសុខភាព សាលារៀន គ្រូបង្រៀន និងខ្វះសេវារដ្ឋបាលសាធារណៈ។ល។ ជាពិសេស ខ្វះប្រព័ន្ធចិញ្ចឹមជីវិតប្រកបដោយនិរន្តរភាព ដែលជាហេតុធ្វើឱ្យពួកគាត់បង្ខំចិត្តចាកចេញពីតំបន់តាំងទីលំនៅថ្មីនេះ ទៅរស់នៅតំបន់ផ្សេងៗ ធ្វើចំណាកស្រុក ឬ លក់ដី និងផ្ទះសម្បទានទាំងនោះ ដើម្បីដោះបំណុល។

- **បញ្ហាខ្វះចន្លោះក្នុងដំណើរការសម្បទានដីសង្គមកិច្ច៖** ការអនុវត្តគម្រោងសម្បទានដីសង្គមកិច្ចមួយចំនួននៅមានចំណុចខ្វះចន្លោះច្រើន ជាហេតុធ្វើឱ្យរាំងស្ទះដំណើរការ និងមិនសម្រេចតាមគោលបំណងគម្រោង។ មានកត្តាប្រឈម៣សំខាន់គឺ ទី១. ការជ្រើសរើសដីជាដីមិនមានសុវត្ថិភាព ជាន់លើដីប្រជាពលរដ្ឋដែលបានកាន់កាប់ប្រើប្រាស់ជាក់ស្តែង ជាហេតុបង្កើតឱ្យមានទំនាស់។ ទី២. ការអភិវឌ្ឍសម្បទានដីសង្គមកិច្ច ខ្វះនូវហេដ្ឋារចនាសម្ព័ន្ធ (តភ្ជាប់ផ្លូវគមនាគមន៍ ប្រព័ន្ធទឹកស្អាត លូ បង្គន់អនាម័យ និងអគ្គិសនី) និងហេដ្ឋារចនាសម្ព័ន្ធសង្គម (សាលារៀន មណ្ឌលសុខភាព ទីតាំងផ្សារ សេវារដ្ឋបាល និងការរក្សាសន្តិសុខ និងឧបករណ៍សម្ភារៈសម្រាប់អភិវឌ្ឍន៍ដី) ដើម្បីធានានូវប្រព័ន្ធចិញ្ចឹមជីវិតប្រកបដោយនិរន្តភាព។ និងទី៣. ការជ្រើសរើសមុខសញ្ញាទទួលដីមិនទាន់មានតម្លាភាព ខ្វះការផ្សព្វផ្សាយព័ត៌មានគម្រោង និងការកំណត់ពេលវេលានៃការដាក់ពាក្យសុំ ការវាយតម្លៃមុខសញ្ញាជាប់ស្ថាពរ និងបម្រុង និងខ្វះយន្តការបណ្តឹងតវ៉ាបន្ទាប់ពីការបិតផ្សាយឡើងវិញក្នុងរយៈពេល២០ថ្ងៃ។

- **បញ្ហាវិវាទដីធ្លីៈ** ករណីវិវាទដីធ្លីជាមួយក្រុមហ៊ុនធំៗ ដែលពាក់ព័ន្ធនឹងគម្រោងសម្បទានដីសេដ្ឋកិច្ច សម្បទានដីតំបន់សេដ្ឋកិច្ចពិសេស គម្រោងអភិវឌ្ឍន៍ទីក្រុង និងបុគ្គលមានអំណាចនៅតែមិនទាន់អាចដោះស្រាយចប់នៅឡើយ ថ្វីបើក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងអាជ្ញាធររដ្ឋបាលថ្នាក់ក្រោមជាតិ បានខិតខំប្រឹងប្រែងដោះស្រាយយ៉ាងណាក្តី។ ជាក់ស្តែងករណីវិវាទទាំងអស់នោះរួមមាន៖
  - ករណីវិវាទដីធ្លីនៅឆ្នាំ២០១៤ រវាងប្រជាពលរដ្ឋចំនួន៦សហគមន៍ស្ថិតក្នុងខ័ណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ និង ក្រុមហ៊ុន Oversea Cambodian International Corporation (OCIC) ។
  - ករណីផលប៉ះពាល់នៃគម្រោងសម្បទានដីអភិវឌ្ឍន៍តំបន់ពាណិជ្ជកម្ម និងទេសចរណ៍ខ្នាតអន្តរជាតិរបស់ក្រុមហ៊ុន Union Development Group Co., Ltd នៅស្រុកបុទុមសាគរ និងគីរីសាគរ ខេត្តកោះកុង។
  - ករណីវិវាទដីធ្លីនៅឆ្នាំ២០១២ រវាងប្រជាពលរដ្ឋឃុំប្រមេរ និងក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច អភិវឌ្ឍដំណាំអំពៅ ឡានហ្វេង និងរ៉ូយហ្វេង នៅស្រុកត្បែងមានជ័យ ខេត្តព្រះវិហារ ។
  - ករណីវិវាទដីធ្លីនៅឆ្នាំ២០១០ រវាងប្រជាពលរដ្ឋចំនួន២៣គ្រួសារ និងក្រុមហ៊ុន សម្បទានដីសេដ្ឋកិច្ច អឹម ឌី អេស ថ្មដា អេស អ៊ី ហ្សិត នៅឃុំថ្មដា ស្រុកវាលវែង ខេត្តពោធិ៍សាត់ ។
  - ករណីផលប៉ះពាល់នៃគម្រោងសម្បទានដីសេដ្ឋកិច្ចបឹងប្រាំ ស្រុកបវេល ខេត្តបាត់ដំបង នាំឱ្យកើតមានទំនាស់រវាងប្រជាពលរដ្ឋ ១៩២គ្រួសារ និង ប្រជាពលរដ្ឋ១២៩៩គ្រួសារ តាំងពីឆ្នាំ២០០៩។
  - ផលប៉ះពាល់នៃគម្រោងដីសម្បទានសេដ្ឋកិច្ច ដំណាំកៅស៊ូរបស់ក្រុមហ៊ុនប៊ិញហ្វឿក ក្រចេះរ៉ាប់ប៊ឺ ១ ខមភេនី លីមីធីត នៅឃុំស្រែឈូក ស្រុកកែវសីមា ខេត្តមណ្ឌលគីរី ក្នុងឆ្នាំ២០១២ នាំឱ្យកើតមានទំនាស់ជាមួយប្រជាពលរដ្ឋជនជាតិដើមភាគតិចចំនួន១៨០គ្រួសាររស់នៅភូមិចក់ចារ ឃុំស្រែឈូក
  - ករណីវិវាទដីធ្លីរវាងប្រជាពលរដ្ឋចំនួន៤៩គ្រួសារ និងក្រុមហ៊ុន KDC នៅភូមិឡពាង ឃុំតាជេស ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង

- ករណីវិវាទដីធ្លីនៅឆ្នាំ២០១៥ រវាងប្រជាពលរដ្ឋ៤៧៦គ្រួសារ និងក្រុមហ៊ុន First Bio-Tech Agricultural (Cambodia) Co., Ltd.ហៅកាត់ថាក្រុមហ៊ុន ចាន់ សុធា, ក្រុមហ៊ុន World Tristar Entertainment Co., Ltd ហៅកាត់ថា ក្រុមហ៊ុន សូ ងួននិងក្រុមហ៊ុន VGP ហៅកាត់ថាក្រុមហ៊ុន ឥណ្ឌា ដែលមានផ្ទៃដីទំនាស់ទំហំ៣១៤៤.១៥ហិកតា ស្ថិតនៅភូមិតេជោពង្រុក ឃុំតេជោអភិវឌ្ឍន៍ ស្រុកឈូក ខេត្តកំពត។
- ករណីវិវាទដីធ្លីនៅឆ្នាំ២០១៣រវាងប្រជាពលរដ្ឋសមាហរណកម្មចំនួន៤៣គ្រួសារ និងលោក សូ ប៉ន ជាអនុភូមិត្រពាំងរុន ពាក់ព័ន្ធនឹងការលក់ទិញដីឱ្យក្រុមហ៊ុនថា ដេអ៊ិនដេម៉ុង ខូអិលធីឌី ដែលមានផ្ទៃដីចំនួន៨២ហិកតា ស្ថិតនៅភូមិជ័យសេនា ឃុំតាកែន ស្រុកឈូក ខេត្តកំពត។
- ករណីវិវាទដីធ្លីនៅឆ្នាំ២០០៨ រវាងប្រជាពលរដ្ឋ៤៥៦គ្រួសារ ជាមួយនឹងលោក គង់ ឡុំ មេបញ្ជាការរងកងទ័ពជើងទឹក កងពលលេខ៣១ ដែលមានផ្ទៃដីទំនាស់ ៩១ ហិកតា ស្ថិតនៅភូមិតេជោអន្លង់ក្មេងលេង ឃុំតេជោអភិវឌ្ឍន៍ ស្រុកឈូក ខេត្តកំពត។
- ករណីវិវាទដីធ្លីនៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០១ រវាងប្រជាពលរដ្ឋចំនួន១០៨ គ្រួសារ ជាមួយនឹងគ្រួសារទាហាន ចំនួន១១គ្រួសារ នៅភូមិស្ទឹងបត់ សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ដែលមានទំហំដីទំនាស់១០ ហិកតា។
- ករណីវិវាទដីធ្លីនៅថ្ងៃទី១ ខែមករា ឆ្នាំ២០០៤ រវាងប្រជាពលរដ្ឋចំនួន៥១គ្រួសារ ជាមួយនឹង លោក ទុយ វណ្ណី សែត រិន សោម សុខេន ដែលមានដីទំនាស់ទំហំ១១៣ ហិកតា ស្ថិតនៅ ភូមិសិលាខ្មែរ ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ។
- ករណីវិវាទដីធ្លីនៅថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០០៨ រវាងប្រជាពលរដ្ឋចំនួន១៧០គ្រួសារ និង លោក ឈឿង សារិត ទាហានកងរថក្រោះ ដែលមានផ្ទៃដីដីទំនាស់ទំហំ៩០,៥៣ ហិកតា ស្ថិតនៅ ភូមិចក្រី ឃុំជប់វារី និង ភូមិចក្រី ឃុំជប់វារី ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ។
- ករណីទំនាស់ដីធ្លីនៅឆ្នាំ២០១៨ រវាងប្រជាពលរដ្ឋចំនួន៣២គ្រួសារ សំបួរមាស ក្រុងកំពង់ចាម ជាមួយនឹងឃុំក្រឡា ស្រុកកំពង់សៀម ជាមួយក្រុមហ៊ុនអគ្គិសនីកម្ពុជា អភិវឌ្ឍន៍ខ្សែបណ្តាញអគ្គិសនី និងសង់ទីស្នាក់ការ ដែលក្រុមហ៊ុនឱ្យសំណងទាប ក្នុង១ម៉ែត្រការ៉េ តម្លៃ ១,៨០ ដុល្លារ ខណៈដែលតម្លៃទីផ្សារ ១ម៉ែត្រការ៉េ តម្លៃ៤៥ដុល្លារ។
- ផលប៉ះពាល់នៃគម្រោងសម្បទានដីសេដ្ឋកិច្ច អភិវឌ្ឍន៍ដំណាំកៅស៊ូ របស់ក្រុមហ៊ុន រ័ត្នសាខន (ហ្សូមវ៉ាង) Rath Sakhorn Coorporation Co. Ltd (Zhom Wang )នៅភូមិសមុទ្រលើ ឃុំសេដា ស្រុកលំផាត់ ខេត្តរតនគិរី។ ក្រុមហ៊ុននេះទទួលបានដីសម្បទានសេដ្ឋកិច្ច ចំនួន៩០០០ហិកតា។ ទំនាស់ដីធ្លីនេះកើតឡើងកាលពីឆ្នាំ ២០១៤ បានប៉ះពាល់ប្រជាជន ចំនួន ២៥៤ គ្រួសារ ដែលមានផ្ទៃដីទំនាស់ចំនួន ២០០០ ហិកតា នៅសហគមន៍ព្រៃឈើភូមិសមុទ្រលើ។
- ផលប៉ះពាល់នៃគម្រោងសម្បទានដីសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ជីង សុងរី (Jing ZhongRi Co., Ltd) វិនិយោគដំណាំកៅស៊ូ និងដំណាំឧស្សាហកម្មនានា នៅភូមិសមុទ្រក្រោម ឃុំសេដា ស្រុកលំផាត់ ខេត្តរតនគិរី។ ករណីនេះកើតនៅឆ្នាំ២០១១ ពាក់ព័ន្ធផ្ទៃដីព្រំប្រទល់ចំនួន ៥០០ ហិកតាដែលមានប្រជាជន ចំនួន ១២៦ គ្រួសារ រវាងព្រំប្រទល់សហគមន៍ និងក្រុមហ៊ុន។

- ផលប៉ះពាល់នៃគម្រោងដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ៧ មករា ជាមួយនឹងសហគមន៍ចំនួន ០៥ភូមិ ស្មើនឹងប្រជាជនចំនួន២៤៧គ្រួសារ រស់នៅភូមិភី នៅសេសាន បាតាង បាដាល នៅអូយ៉ាដាវ តាំងសេ និងតាំងលោម នៅញ៉ាង ស្រុកអណ្តូងមាស ខេត្តរតនៈគិរី ដែលពាក់ព័ន្ធនឹងដីចំនួន ៦០០ ហិកតា។
- ករណីវិវាទដីធ្លីរវាង អាជ្ញាធរអប្សរា ជាមួយនឹងប្រជាពលរដ្ឋចំនួន២៧គ្រួសារ ប្តឹងទាមទារដីទំហំ ១១៤ហិកតា នៅភូមិតានី ឃុំរុនតាឯក ស្រុកបន្ទាយស្រី ខេត្តសៀមរាប ដែលពាក់ព័ន្ធនឹងគម្រោងអភិវឌ្ឍន៍ភូមិធម្មជាតិ កាលពីឆ្នាំ២០០៥។
- ករណីវិវាទដីធ្លីរវាងប្រជាពលរដ្ឋចំនួន៩០គ្រួសាររស់នៅភូមិតាពេន ជាមួយនឹងប្រជាពលរដ្ឋភូមិស្រះខ្វាវ ដែលប្តឹងទាមទារដីទំហំ៩០ហិកតា ស្ថិតនៅភូមិតាពេន ឃុំត្បែង ស្រុកបន្ទាយស្រី ខេត្តសៀមរាប។

➢ **បញ្ហាអូសបន្លាយពេលក្នុងការផ្តល់ប័ណ្ណកម្មសិទ្ធិដីជាលក្ខណៈប្រព័ន្ធ៖** ចាប់តាំងពីឆ្នាំ២០១៩ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានការតាំងចិត្តខ្ពស់ក្នុងការពន្លឿនការចុះបញ្ជីដីធ្លីជូនប្រជាពលរដ្ឋ ប៉ុន្តែជាក់ស្តែង ការផ្តល់ប័ណ្ណកម្មសិទ្ធិជូនប្រជាពលរដ្ឋនៅតែបន្តអូសបន្លាយពេលយូរ។

➢ **បញ្ហាកង្វះការទទួលខុសត្រូវផ្នែកសង្គមរបស់សាជីវកម្មនៅតែបន្តកើតមានក្នុងដំណើរការអនុវត្តគម្រោងអភិវឌ្ឍន៍៖**

ក្រុមហ៊ុនសម្បទានមួយចំនួន ខ្វះការទទួលខុសត្រូវក្នុងការអនុវត្តគម្រោងរបស់ខ្លួន បង្កឱ្យមានផលប៉ះពាល់ដល់បរិស្ថាន និងសង្គមដោយសារការប្រើប្រាស់ជីគីមី ថ្នាំពុល ការទុកដាក់កាកសំណល់មិនបានល្អរបស់ក្រុមហ៊ុនអភិវឌ្ឍន៍ទំនប់វារីអគ្គីសនី ប្រព័ន្ធធារាសាស្ត្រ និងក្រុមហ៊ុនអភិវឌ្ឍន៍សម្បទានសេដ្ឋកិច្ច ធ្វើឱ្យប៉ះពាល់ដល់គុណភាពទឹកទន្លេ ស្ទឹង បឹងបួរ និងបង្ហូរចូលដីស្រែ ចំការ បណ្តាលឱ្យប៉ះពាល់សុខភាពមនុស្ស សត្វ និងខូចខាតផលដំណាំស្រូវ បន្លែរបស់ប្រជាពលរដ្ឋ។ ជាមួយគ្នានេះ មានក្រុមហ៊ុនមួយចំនួនបានប្រើយុទ្ធសាស្ត្របិទផ្លូវទំនាក់ទំនងរវាងប្រជាពលរដ្ឋ និងអ្នករស់នៅខាងក្រៅ នាំឱ្យប៉ះពាល់ដល់ការប្រកបមុខរបរប្រចាំថ្ងៃ និងទំនាក់ទំនងសង្គម។ ក្រុមហ៊ុនខ្លះទៀត បានយកគ្រឿងចក្រឈូសឆាយកាយព្រំដីរុះរើផ្ទះ និងបណ្តេញប្រជាពលរដ្ឋ។

➢ **ទំនាស់ដីរដ្ឋបាលដែលប្រជាជនកាន់កាប់ជាក់ស្តែង និងបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងដីតំបន់ការពារ ឬដីគម្របព្រៃ៖** ដូចដែលយើងទាំងអស់គ្នាដឹងហើយថា ការទទួលបានដីភោគៈរបស់ប្រជាពលរដ្ឋកម្ពុជាមាន៥ដំណាក់កាលរួមមាន ទី១.ការបែងចែកដីនៅសម័យរដ្ឋកម្ពុជាឆ្នាំ១៩៨៩ ទី២. ការបែងចែកដីជូនប្រជាពលរដ្ឋធ្វើមាតុភូមិនិវត្តន៍ឆ្នាំ១៩៩១-១៩៩៣ ទី៣. ផ្តល់ដីជូនគ្រួសារអតីតកងកម្លាំងខ្មែរក្រហមសមាហរណកម្ម ឆ្នាំ១៩៩៨ ទី៤. ការអនុវត្តគម្រោងសម្បទានសង្គមកិច្ច ចាប់ពីឆ្នាំ២០០៣ រហូតមក និង ទី៥. យុទ្ធនាការអនុវត្តបទបញ្ជាលេខ០១។ បញ្ហាប្រឈមនៃការកាន់កាប់ដីភោគៈរបស់ប្រជាពលរដ្ឋដែលទទួលបានក្នុងដំណាក់កាលពីទី១ ដល់ទី៣ ត្រូវបានទទួលស្គាល់សិទ្ធិភោគៈត្រឹមត្រូវតាមច្បាប់

ក្នុងច្បាប់ភូមិបាលឆ្នាំ២០០១ ដែលទីតាំងដីទាំងនេះស្ថិតនៅក្នុងដែនដីរដ្ឋបាលភូមិ ឃុំ ស្រុក ត្រូវបានទទួលស្គាល់ និងចុះបញ្ជីផ្លូវការដោយក្រសួងមហាផ្ទៃ ប៉ុន្តែវាក៏ស្ថិតនៅក្នុងតំបន់ការពារ ឬ តំបន់ជាប់គម្របព្រៃឈើ ដែលត្រូវបានការពារដោយព្រះរាជក្រឹត្យឆ្នាំ១៩៩៣ ត្រូវបានបកស្រាយ ឬចំណាត់ថ្នាក់ថាជាការកាន់កាប់ដីសាធារណៈរបស់រដ្ឋខុសច្បាប់ អាចប្រឈមនឹងការដកហូត ការមិនទទួលបានសំណងផលប៉ះពាល់ ក្នុងករណីមានការផ្តល់សម្បទានដីឱ្យក្រុមហ៊ុនអភិវឌ្ឍន៍ និងបាត់បង់ កម្មសិទ្ធិ។

## ១.៣ អនុសាសន៍ និងសំណូមពរ

- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ គួរផ្តល់ឱកាសទូលំទូលាយដល់អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធផ្សេងៗទៀត ដើម្បីចូលក្នុងដំណើរការធ្វើវិសោធនកម្មច្បាប់ភូមិបាល ឆ្នាំ២០០១ និងសហការរៀបចំកិច្ចពិគ្រោះយោបល់ឱ្យបានទូលំទូលាយ ទាំងថ្នាក់តំបន់ និងថ្នាក់ជាតិ ដើម្បីប្រមូលមតិយោបល់ និងធាតុចូលពីគ្រប់អ្នកពាក់ព័ន្ធ សម្រាប់ធ្វើឱ្យច្បាប់នេះកាន់តែមានគុណភាពល្អប្រសើរឡើងថែមទៀត និងប្រសិទ្ធភាពនៃការអនុវត្ត។

- រាជរដ្ឋាភិបាលកម្ពុជា គួរពិនិត្យពិចារណារៀបចំគោលការណ៍ណែនាំ ឬ គោលនយោបាយជាតិ ស្តីពីសំណងសមរម្យ និងយុត្តិធម៌ លើផលប៉ះពាល់នៃគម្រោងអភិវឌ្ឍន៍ ដើម្បីបំពេញតម្រូវការអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់ប្រទេសជាតិ ដោះស្រាយបញ្ហាកំពុងប្រឈម និងសម្រេចគោលបំណងនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពនៅកម្ពុជា(CSDG)។ ជាពិសេស ឆ្លើយតបនឹងតម្រូវការច្បាប់ស្តីពីអស្សាមិករណ៍របស់ប្រទេសកម្ពុជា ដែលតម្រូវឱ្យបង្កើតបទដ្ឋានគតិយុត្តក្រោមច្បាប់បន្ថែមទៀត ដើម្បីអនុវត្តបំពេញបន្ថែម។ ហេតុដូច្នេះ រាជរដ្ឋាភិបាលគួរធ្វើសិក្សាស្រាវជ្រាវនូវបទពិសោធន៍ល្អៗនៃការអនុវត្តគម្រោងកន្លងមក ដូចជា គម្រោងអភិវឌ្ឍន៍របស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ធនាគារពិភពលោក (WB) និងគម្រោងអភិវឌ្ឍន៍របស់JICA និងចំណុចខ្វះចន្លោះមួយចំនួនផ្សេងទៀតរបស់គម្រោងអភិវឌ្ឍន៍របស់ក្រុមហ៊ុនឯកជនជាតិ និងអន្តរជាតិ ដែលមិនមានគោលនយោបាយការពារសុវត្ថិភាព (Safe Guard Policy) ក្នុងការអភិវឌ្ឍ ដែលជាដើមចមធ្វើឱ្យមានទំនាស់យូរអង្វែង មិនអាចដោះស្រាយផលប៉ះពាល់ប្រកបដោយយុត្តិធម៌ និងការការពារផលប៉ះពាល់ដល់បរិស្ថាន។

- រាជរដ្ឋាភិបាលកម្ពុជា ជាពិសេស ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអាជ្ញាធរថ្នាក់ក្រោមជាតិដែលពាក់ព័ន្ធ គួរបន្តពង្រឹងប្រសិទ្ធភាពការងារសិក្សាស្រាវជ្រាវ ធ្វើបច្ចុប្បន្នភាពសហគមន៍ក្រីក្រ ដែលតាំងទីលំនៅ ក្នុងតំបន់មិនរៀបរយ ដើម្បីរៀបចំផែនការមេដោះស្រាយជូនពួកគាត់ឱ្យមានសុវត្ថិភាពដីធ្លី មានផ្ទះសំបែងសមរម្យ មានហេដ្ឋារចនាសម្ព័ន្ធ សន្តិសុខ សុវត្ថិភាព និងមានអនាម័យល្អ តាមរយៈគោលការណ៍ជាមូលដ្ឋានចំនួន២ គឺ ការអភិវឌ្ឍនៅនឹងកន្លែង និងការតាំងទីលំនៅថ្មី ដែលមានទីតាំងនៅមិនឆ្ងាយពីទីតាំងចាស់ ធានាថាមិនបាត់បង់ទាំងស្រុងនូវអ្វីៗដែលពួកគាត់ធ្លាប់មាន ប្រើប្រាស់ អាស្រ័យផល និងទំនាក់ទំនងសង្គម។ ជាពិសេស ការលើកកម្ពស់

ការសិក្សាអប់រំដល់កូនចៅរបស់ពួកគាត់ ទាំងជំនាញ និងចំណេះដឹងទូទៅឱ្យបានខ្ពង់ខ្ពស់ គឺជាកូនសោរមួយនៃយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រដ៏មានប្រសិទ្ធភាព និងនិរន្តរភាពពិតប្រាកដ។ ការផ្តល់ជម្រើសអភិវឌ្ឍនៅនឹងកន្លែង ការសាងសង់ជាអគារផ្តល់ជូនប្រជាពលរដ្ឋក្រីក្រ ឬ ការបែងដីឡូត៍ ដូចសាលារាជធានីភ្នំពេញអនុវត្តនៅប្រឡាយស្ទឹងមានជ័យ គឺជាមេរៀនគំរូដ៏ល្អមួយ ដែលទទួលបានការគាំទ្រ និងកោតសរសើរពីប្រជាពលរដ្ឋ និងគ្រប់តួអង្គពាក់ព័ន្ធទាំងអស់។

- រាជរដ្ឋាភិបាលកម្ពុជាគួរពង្រឹងគុណភាពនៃការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម (EIA) បន្ថែមទៀត អនុវត្តឱ្យបានត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេស ដោយមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធ ចាប់តាំងពីការសិក្សា និងពិគ្រោះយោបល់ជាសាធារណៈ ដើម្បីធានានូវ ព័ត៌មានពិតប្រាកដ និងការរៀបចំផែនការមេដោះស្រាយផលប៉ះពាល់ និងការត្រួតពិនិត្យជាប្រចាំរាល់ដំណើរការ អនុវត្តគម្រោង។ EIA នេះត្រូវធ្វើមុនដំណើរការអនុវត្តគម្រោង។ ជាមួយគ្នានេះ ក្រសួងមានសមត្ថកិច្ចពាក់ព័ន្ធ គួរដោះស្រាយផលប៉ះពាល់ដីធ្លី លំនៅឋាន សេដ្ឋកិច្ច និងវប្បធម៌របស់ប្រជាពលរដ្ឋមូលដ្ឋាន ដោយយករបាយការណ៍ EIA ជាភស្តុតាង ច្បាប់ គោលនយោបាយ និងជម្រើសឯកភាពរបស់ភាគី ធ្វើជាមូលដ្ឋានក្នុងការផ្តល់សំណង។ ចំណែកទីតាំងលំនៅឋានថ្មី ត្រូវរៀបចំអភិវឌ្ឍន៍ឱ្យរួចរាល់ជាមុន រួមមាន សំណង់ផ្ទះមានគុណភាព ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ប្រព័ន្ធលូ បង្គន់អនាម័យ ភ្លើង ទឹកស្អាត មណ្ឌលសុខភាព សាលារៀន គ្រូបង្រៀន សេវារដ្ឋបាលសាធារណៈនិង ប្រព័ន្ធចិញ្ចឹមជីវិតប្រកបដោយនិរន្តរភាព ដើម្បីធានាថា ការផ្លាស់ប្តូរទីលំនៅទៅតំបន់ថ្មី មានភាពល្អប្រសើរជាងទីតាំងចាស់ ដែលជាវត្ថុបំណងនៃគម្រោងអភិវឌ្ឍន៍របស់ប្រទេសជាតិយើង។ ទីតាំងលំនៅឋានថ្មី គួរពិចារណាអំពីចម្ងាយ ពោលគឺ រៀបចំនៅជិតទីតាំងចាស់តាមដែលអាចធ្វើបាន ដើម្បីកាត់បន្ថយការបាត់បង់អ្វីៗដែលពួកគាត់ធ្លាប់មាន។

- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងអាជ្ញាធររដ្ឋបាលថ្នាក់ក្រោមជាតិ គួរធ្វើការសិក្សាស្រាវជ្រាវបន្ថែមទៀត ដើម្បីត្រួតពិនិត្យ វាយតម្លៃលទ្ធផលការងារអនុវត្តគម្រោងដីសម្បទានសង្គមកិច្ច និងកែសម្រួលផែនការយុទ្ធសាស្ត្រ និងការអនុវត្តគម្រោងឱ្យកាន់តែមានប្រសិទ្ធភាពល្អប្រសើរឡើងថែមទៀត តាមរយៈការពង្រឹងកិច្ចការមូលដ្ឋានចំនួន៣ រួមមាន៖

  ទី១. ការជ្រើសរើសដីសម្រាប់សម្បទានសង្គមកិច្ច ត្រូវតែជាដីឯកជនរបស់រដ្ឋដែលបានចុះបញ្ជីរួចហើយ ធានាថាជាដីមានសុវត្ថិភាព មិនមានទំនាស់។

  ទី២. ការអភិវឌ្ឍដីនៅតំបន់សម្បទានសង្គមកិច្ច ត្រូវរៀបចំឱ្យរួចរាល់នូវហេដ្ឋារចនាសម្ព័ន្ធ (ការតភ្ជាប់ផ្លូវគមនាគមន៍ ប្រព័ន្ធទឹកស្អាត លូ បង្គន់អនាម័យ និងអគ្គិសនី) ហេដ្ឋារចនាសម្ព័ន្ធសង្គម (សាលារៀន មណ្ឌលសុខភាព ទីតាំងផ្សារ សេវារដ្ឋបាល សាធារណៈ ការរក្សាសន្តិសុខ និងឧបករណ៍សម្ភារៈសម្រាប់អភិវឌ្ឍន៍ដី) និងរៀបចំឱ្យមានប្រព័ន្ធចិញ្ចឹមជីវិតប្រកបដោយ និរន្តរភាព។

  ទី៣. ការជ្រើសរើសមុខសញ្ញាទទួលដីឱ្យចំអ្នកក្រគ្មានដីពិតប្រាកដប្រកបដោយតម្លាភាព។ កិច្ចការនេះ ក្រុមប្រឹក្សាឃុំសង្កាត់មានតួនាទីសំខាន់ណាស់ក្នុងការផ្សព្វផ្សាយព័ត៌មានគម្រោង ការកំណត់

ពេលវេលានៃការដាក់ពាក្យសុំ ការវាយតម្លៃមុខសញ្ញាជាប់ស្ពាន និងបម្រុង និងអនុវត្តយន្តការបណ្តឹងតវ៉ាបន្ទាប់ពីការបិតផ្សាយឡើងវិញក្នុងរយៈពេល២០ថ្ងៃ និងដោះស្រាយដោយយុត្តិធម៌។ មេរៀនប្រតិបត្តិល្អនៃការអនុវត្តគម្រោងដីសម្បទានសង្គមកិច្ចនៅភូមិស្នាតេជោ ឃុំបល្ល័ង្គ ស្រុកប្រាសាទបាគង ខេត្តសៀមរាប គឺជាគំរូល្អ (Good Model) ដែលរាជរដ្ឋាភិបាលគួរបន្តយកទៅអនុវត្តនៅបណ្តាគម្រោងផ្សេងៗទៀត ដែលបានរៀបចំដីអភិវឌ្ឍន៍ទីតាំងដីសម្បទានសង្គមកិច្ចត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេស មានហេដ្ឋារចនាសម្ព័ន្ធល្អគ្រប់គ្រាន់ និងប្រព័ន្ធចិញ្ចឹមជីវិតប្រកបដោយនិរន្តរភាព។

- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងអាជ្ញាធររដ្ឋបាលថ្នាក់ក្រោមជាតិ គួរបន្តពង្រឹងយន្តការសុរិយោដី ក្រុមការងារដោះស្រាយវិវាទដីធ្លីឱ្យកាន់តែមានប្រសិទ្ធភាពថែមទៀត តាមរយៈការផ្តល់ការគាំទ្រ ធនធានគ្រប់គ្រាន់ និងលើកទឹកចិត្តពួកគាត់ចុះស្រាវជ្រាវករណីវិវាទនិមួយៗឱ្យបានច្បាស់លាស់ រកឱ្យឃើញនូវព័ត៌មានពិតប្រាកដ ពាក់ព័ន្ធនឹងប្រវត្តិដី សកម្មភាពទំនាស់ ចំណុចវិវាទ មូលហេតុវិវាទ តួអង្គពាក់ព័ន្ធនឹងវិវាទ បទដ្ឋានគតិយុត្ត និងរៀបចំផែនការដោះស្រាយ។ ការសម្របសម្រួលដោះស្រាយគួរឈរលើគោលការណ៍មូលដ្ឋាន៤សំខាន់ រួមមាន៖

  ទី១. សម្របសម្រួលដោះស្រាយឱ្យមានបរិយាបន្នរបស់ភាគីពាក់ព័ន្ធទាំងអស់តាំងពីដំណាក់កាលសិក្សាស្រាវជ្រាវ ឬស៊ើបអង្កេត ករណីវិវាទរហូតដល់វេទិកាពិភាក្សាដោះស្រាយបញ្ចប់សំណុំរឿង ដើម្បីធានាមានព័ត៌មានពេញលេញ និងពិតប្រាកដ។ ការបញ្ចូលភាគីពាក់ព័ន្ធទាំងអស់ក្នុងដំណើរការដោះស្រាយវិវាទ គឺជាកត្តាសំខាន់ណាស់ ដើម្បីឱ្យភាគីទាំងអស់ឈ្វេងយល់ការងារពីគ្នាទៅវិញទៅមក និងអនុវត្តសកម្មភាពការងារតាមការទទួលខុសត្រូវរបស់ខ្លួនដើម្បីបំពេញឱ្យគ្នាទៅវិញទៅមកក្នុងការឈានទៅសម្រេចបាននូវគោលដៅលទ្ធផលរួម និងបញ្ចៀសបានការយល់ច្រឡំ ឬ ការប្រើប្រាស់ព័ត៌មានមិនត្រឹមត្រូវ ដែលអាចបង្កើតជាឧបសគ្គរាំងស្ទះដល់លទ្ធផលនៃការដោះស្រាយទំនាស់។

  ទី២. អាជ្ញាធរមានសមត្ថកិច្ច គួរមានការតាំងចិត្តខ្ពស់បន្ថែមទៀតក្នុងការស្តាប់ និងពិចារណានូវរាល់ការលើកឡើងរបស់ភាគីពាក់ព័ន្ធ ពិសេសភាគីប្រជាពលរដ្ឋដែលទទួលរងផលប៉ះពាល់ ដូចជាបញ្ហាប្រឈម កង្វល់ តម្រូវការ សំណូមពរ និងអនុសាសន៍ ដើម្បីផ្ទៀងផ្ទាត់ជាមួយរបាយការណ៍ការពិត បទដ្ឋានគតិយុត្ត និងកត្តារួមផ្សំសំខាន់ៗមួយចំនួនទៀត សម្រាប់ឆ្លើយតប និងសម្រេចដោយមានហេតុផលត្រឹមត្រូវអាចទទួលយកបានទាំងអស់គ្នា ប្រកបដោយសោមនស្សរីករាយក្នុងការបញ្ចប់សំណុំរឿង។ ការដោះស្រាយទាំងឡាយណា ដែលប្រើប្រាស់អំណាច បិទបាំងព័ត៌មាន ការពារផលប្រយោជន៍បុគ្គល ឬ ភាគីណាមួយ នាំឱ្យខូចផលប្រយោជន៍របស់ភាគីម្ខាងទៀត គឺជាមូលហេតុនៃភាពបរាជ័យក្នុងការដោះស្រាយទំនាស់ និងជាមេរៀននៃការដោះស្រាយមិនចេះចប់ ពោលគឺ កំណត់ហេតុរបស់អាជ្ញាធរ សរសេរថា ដោះស្រាយចប់ ប៉ុន្តែប្រជាពលរដ្ឋនៅតែបន្ត បណ្តឹង។

ទី៣. ការបង្កើតជម្រើសឱ្យបានច្រើន គឺជាចំណុចគន្លឹះនៃការសម្របសម្រួលដោះស្រាយវិវាទដីធ្លី។ ភាគីពាក់ព័ន្ធ ពិសេសគូភាគីវិវាទត្រូវធ្វើការសម្របសម្រួលបង្កើតឱ្យមានជម្រើសច្រើន តាមរយៈការធ្វើឱ្យមានសម្បទានផលប្រយោជន៍របស់ភាគីវិវាទជូនគ្នាទៅវិញទៅមក ដោយប្រកាន់យកគោលការណ៍ឈ្នះឈ្នះ ក្នុងករណីអាជ្ញាធរមានសមត្ថកិច្ចរកឃើញថា មិនមាន ភាគីណាមួយប្រើប្រាស់អំណាចប្រព្រឹត្តល្មើសច្បាប់ដោយចេតនារំលោភយកទ្រព្យសម្បត្តិរបស់ភាគីម្ខាងទៀតទេ។ ករណីខ្លះ រាជរដ្ឋាភិបាលកម្ពុជាក៏អាចធ្វើសម្បទានបំពេញបន្ថែម ឬ ជំនួសផងដែរ ដើម្បីដោះស្រាយចំណុចខ្វះចន្លោះនៃច្បាប់ ឬ ការ អនុវត្តណាមួយ។

ទី៤. ការផ្សព្វផ្សាយជាសាធារណៈនូវដំណោះស្រាយជោគជ័យ និងបន្តនីតិវិធីចុះបញ្ជីដីធ្លី ផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីជូនភាគីសម្រាប់វិធានការណ៍ការពារនាពេលអនាគត។

ម្យ៉ាងវិញទៀត រាជរដ្ឋាភិបាលកម្ពុជា គួរពិនិត្យការគ្រប់គ្រងដីធ្លី និងការដោះស្រាយវិវាទដីធ្លីដែលពាក់ព័ន្ធជាមួយអាជ្ញាធរអប្សរាឡើងវិញដើម្បីកំណត់តំបន់អប្សរា ការផ្សព្វផ្សាយព័ត៌មានដល់ប្រជាពលរដ្ឋឱ្យយល់ច្បាស់ចំពោះព្រំប្រទល់ ទីតាំង និងប្រភេទ សំណង់ដែលអនុញ្ញាតឱ្យសាងសង់ ឬ ជួសជុល ដែលមានចែងក្នុងអនុក្រឹត្យ និងឯកសារពាក់ព័ន្ធ ដើម្បីទប់ស្កាត់អំពើពុករលួយ ការទប់ស្កាត់វិវាទដែលកើតឡើងដោយសារការបកស្រាយខុសគ្នា និងពន្លឿនការដោះស្រាយបញ្ហាវិវាទដីធ្លីក្នុងតំបន់អប្សរា ឱ្យមានគណនេយ្យភាព និងយុត្តិធម៌។

- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ គួរពន្លឿនសកម្មភាពចុះវាស់វែងដី និងចេញប័ណ្ណកម្មសិទ្ធិជូនប្រជាពលរដ្ឋឱ្យបានលឿនបន្តិចទៀត ដោយបន្ថែមធនធានមនុស្សមានសមត្ថភាព ការគាំទ្រសម្ភារៈ ថវិកា បច្ចេកទេស លើកទឹកចិត្តដល់មន្ត្រីសកម្ម និងបើកឱ្យមានការចូលរួមទូលំទូលាយពីក្រុមអង្គការសង្គមស៊ីវិល និងគ្រប់អ្នកពាក់ព័ន្ធផ្សេងទៀតដែលមានសកម្មភាពគម្រោង ដើម្បីកៀរគរធនធានធានានូវការអនុវត្តឱ្យបានត្រឹមត្រូវតាមតួនាទី និងការទទួលខុសត្រូវស្របតាមច្បាប់ និងបទដ្ឋានគតិយុត្តជាធរមាន។ ជំរុញឱ្យមានកិច្ចប្រជុំជាប្រចាំ ជាមួយអង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍ ដើម្បីចែករំលែកព័ត៌មាន និងរៀបចំផែនការសកម្មភាពសម្រាប់អនុវត្តបំពេញគ្នា ក្នុងគោលបំណងសម្រេចលទ្ធផលរួម។

- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធផ្សេងទៀត គួរពង្រឹងការពិនិត្យតាមដាន និងវាយតម្លៃរាល់ដំណើរការអនុវត្តផែនការមេរបស់ក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ច ក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ចពិសេស និងសម្បទានផ្សេងៗទៀត ដើម្បីធានាថាការអភិវឌ្ឍនេះមិនមានផលប៉ះពាល់ដល់សង្គម និងមានកិច្ចការពារបរិស្ថាន ពោលគឺ ដោះស្រាយទំនាស់ដីធ្លីជាមួយប្រជាពលរដ្ឋប្រកបដោយយុត្តិធម៌ មិនមានការបំពុលបរិស្ថាន និងកាប់បំផ្លាញព្រៃឈើ។ ជាពិសេស តើក្រុមហ៊ុនទាំងនេះបានអនុវត្តតាមផែនការមេ ដូចមានចែងក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់សង្គម និងបរិស្ថាន (EIA) ដែរឬទេ? តើក្រុមហ៊ុនទាំងនេះ មានការទទួលខុសត្រូវផ្នែកសង្គម បានចូលរួមអភិវឌ្ឍន៍សហគមន៍ និងថែ

រក្សា និងដាំឈើឡើងវិញដែរ ឬទេ?។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលកម្ពុជា ត្រូវតែដាក់ទណ្ឌកម្មចំពោះក្រុមហ៊ុនទាំងឡាយណា ដែលមិនគោរពកិច្ចសន្យាសម្បទានជាធរមាន បានបង្កផលប៉ះពាល់សង្គម និងបរិស្ថាន ដូចជាការពិន័យ ទោសព្រហ្មទណ្ឌ និងដកហូតយកដីសម្បទានទាំងនោះមកវិញ ដើម្បីផ្តល់ជាសម្បទានសង្គមកិច្ចដល់ប្រជាពលរដ្ឋក្រីក្រគ្មានដីប្រើប្រាស់ និងស្តារព្រៃឈើឡើងវិញ។

- រាជរដ្ឋាភិបាលកម្ពុជា គួរពន្លឿនការសិក្សាស្រាវជ្រាវ ធ្វើបច្ចុប្បន្នភាពដីដែលប្រជាពលរដ្ឋកាន់កាប់ជាក់ស្តែងឱ្យបានត្រឹមត្រូវច្បាស់លាស់ ធ្វើអនុប្បយោគដីកាត់ឆ្វៀល ចុះបញ្ជីដីជាលក្ខណៈប្រព័ន្ធ ឬសមូហភាពជនជាតិដើមភាគតិច និងផ្តល់ប័ណ្ណកម្មសិទ្ធិជូនប្រជាពលរដ្ឋ ដើម្បីឱ្យពួកគាត់ទទួលបានកម្មសិទ្ធិពេញលេញ។ រាជរដ្ឋាភិបាលកម្ពុជា គួររៀបចំការបោះបង្គោល ឬផ្លាកសញ្ញាកំណត់ព្រំដីរបស់រដ្ឋ និងដីបុគ្គលឯកជនឱ្យបានច្បាស់លាស់ ព្រមទាំងធ្វើការផ្សព្វផ្សាយជាសាធារណៈឱ្យបានទូលំទូលាយ។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលកម្ពុជា គួរពិនិត្យមើលឡើងវិញនូវរាល់ច្បាប់ និងបទដ្ឋានគតិយុត្តទាំងឡាយណា ដែលមានភាពចម្រូងចម្រាស់គ្នាឱ្យមានខ្លឹមសារស្របគ្នា និងបំពេញគ្នាទៅវិញទៅមក ដើម្បីប្រសិទ្ធភាព និងប្រសិទ្ធផលនៃការអនុវត្ត។

# ២. ប្រធានបទស្តីពីសិទ្ធិជនជាតិដើមភាគតិច

## ២.១ សមិទ្ធផល

- ត្រឹមឆ្នាំ២០២០ក្រសួងអភិវឌ្ឍន៍ជនបទបានទទួលស្គាល់ស្វ័យអត្តសញ្ញាណជនជាតិដើមភាគតិចសរុបចំនួន១៥០សហគមន៍។
- ត្រឹមឆ្នាំ២០២០ ក្រសួងមហាផ្ទៃបានចុះបញ្ជីសហគមន៍ជនជាតិដើមភាគតិចជានីតិបុគ្គលសរុបចំនួន១៥០សហគមន៍។
- ត្រឹមឆ្នាំ២០២០ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានចុះបញ្ជីដីសមូហភាព និងបែងចែកប័ណ្ណកម្មសិទ្ធិសមូហភាពចំនួន៣០សហគមន៍។
- រាជរដ្ឋាភិបាលកម្ពុជា បានធ្វើយុទ្ធនាការកាត់ឆ្វៀលដីពីតំបន់ការពារធម្មជាតិ ឬ ច្រករបៀងបរិស្ថានសម្រាប់ការចុះបញ្ជីដីរដ្ឋ ការចុះបញ្ជីដីជាប្រព័ន្ធ និងការចុះបញ្ជីដីសមូហភាពជនជាតិដើមភាគតិចចាប់ផ្តើមពីខេត្តមណ្ឌលគិរី។
- រាជរដ្ឋាភិបាលកម្ពុជា បានបង្កើតតំបន់ការពារធម្មជាតិ បឹងយ៉ាក់ឡោម យ៉ាក់កាវ៉ា បឹងយក្ខឡោម បឹងលំកុដនៅខេត្តរតនគិរី កែវសីមា និងស្រែពក ខេត្តមណ្ឌលគិរី។
- រាជរដ្ឋាភិបាលកម្ពុជា បានទទួលស្គាល់ការបង្កើតតំបន់ទេសចរណ៍ធម្មជាតិក្នុងព្រៃបម្រុងទុក ដីកម្មសិទ្ធិសមូហភាពសហគមន៍ជនជាតិដើមភាគតិច។
- រាជរដ្ឋាភិបាលកម្ពុជា បានទទួលស្គាល់ការបង្កើតសហគមន៍នេសាទក្នុងកម្មសិទ្ធិសមូហភាពជនជាតិដើមភាគតិច។

- រាជរដ្ឋាភិបាលកម្ពុជា បានផ្តល់សេវាសង្គម រួមមាន ផ្លូវក្នុងសហគមន៍ បង្គន់អនាម័យ (បន្ទប់ទឹក នៅតំបន់ទេសចរណ៍តេទឹកពុះ) សាលារៀន និងកម្មវិធីសិក្សា ដោយបានដាក់បញ្ចូលគ្រូបង្រៀនពីរភាសាទៅក្នុងក្របខ័ណ្ឌរដ្ឋ និងផ្តល់គ្រូបង្រៀនសិស្សតាមផ្ទះដល់ជនជាតិដើមភាគតិច។
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានផ្តល់បច្ចេកទេសកសិកម្មដូចជា ចិញ្ចឹមសត្វ និងដាំបន្លែ...។
- រាជរដ្ឋាភិបាលកម្ពុជា បានផ្តល់ថវិកាដល់គ្រួសារក្រីក្រក្នុងស្ថានភាពវិបត្តិកូវីត១៩។
- នាយកដ្ឋានអភិវឌ្ឍន៍ជនជាតិភាគតិចនៃក្រសួងអភិវឌ្ឍន៍ជនបទបានដឹកនាំរៀបចំសេចក្តីព្រាងផែនការយុទ្ធសាស្ត្រអភិរក្ស និងអភិវឌ្ឍន៍ជនជាតិដើមភាគតិច។
- រាជរដ្ឋាភិបាលកម្ពុជា កំពុងធ្វើការកែទម្រង់ច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ច្បាប់ស្តីពីជលផល។
- រាជរដ្ឋាភិបាលកម្ពុជា បានផ្តល់ប័ណ្ណក្រីក្រដល់ជនជាតិដើមភាគតិច។
- រាជរដ្ឋាភិបាលកម្ពុជា បានផ្សព្វផ្សាយនូវវិធីការពារជំងឺ កូវីដ១៩ តាមរយៈវីដេអូ ដល់ជនជាតិដើមភាគតិច។
- រាជរដ្ឋាភិបាលកម្ពុជា បានផ្សព្វផ្សាយពីជំងឺគ្រុនចាញ់ និងគ្រុនឈាមដល់ជនជាតិដើមភាគតិច។

## ២.២ បញ្ហាប្រឈម

- **ការព្រួយបារម្ភណ៍ពីការបាត់បង់អត្តសញ្ញាណ វប្បធម៌ និង ប្រពៃណីជនជាតិដើមភាគតិច** ដោយសារការទទួលស្គាល់ស្វ័យអត្តសញ្ញាណជនជាតិដើមភាគតិចនៅមានភាពយឺតយ៉ាវ ខ្វះការផ្សព្វផ្សាយពីផលប្រយោជន៍នៃការទទួលបានស្វ័យអត្តសញ្ញាណជនជាតិដើមភាគតិច មិនសូវមានការលើកកម្ពស់វប្បធម៌ និងប្រពៃណីជនជាតិដើមភាគតិចពីអាជ្ញាធរពាក់ព័ន្ធ ធ្វើឱ្យសមាជិកសហគមន៍មួយចំនួនស្ទាក់ស្ទើរក្នុងការចូលរួម ព្រមទាំងការទទួលយកវប្បធម៌ថ្មីពីខាងក្រៅ។ ម្យ៉ាងវិញទៀត ការទន្ទ្រានកាន់កាប់ដីនៅតំបន់ការពារ ដីព្រៃជំនឿ ព្រៃតំណម ព្រៃអារក្ស និងតំបន់កប់សពរបស់សហគមន៍ពីអ្នកខាងក្រៅ ក៏ជាមូលហេតុធំដែលកំពុងកើតឡើងដែរដូចករណីភ្នំដោះក្រមុំ និងភ្នំរ៉ាដាងក្បាលអូរច្បារ ស្ថិតនៅក្នុងខេត្តមណ្ឌលគិរីជាដើម ដែលអំពើនេះប្រៀបដូចជាការរំលោភបំពានលុបបំបាត់វប្បធម៌ ប្រពៃណី អត្តសញ្ញាណ និងជីវភាពរបស់ជនជាតិដើមភាគតិច ពីព្រោះអត្តសញ្ញាណ វប្បធម៌ ប្រពៃណី និងជីវភាពរបស់ពួកគាត់ពឹងផ្អែកលើដីធ្លី និងធនធានធម្មជាតិ។

- **ការចុះបញ្ជីដីសមូហភាពសហគមន៍ជនជាតិដើមភាគតិចមានភាពយឺតយ៉ាវ** ដោយសារមានកត្តារាំងស្ទះផ្នែកបច្ចេកទេស និងធនធានមួយចំនួនដូចជា ដំណើរការនៃការកសាងផែនទីបឋមមានលក្ខណៈស្មុគស្មាញ ត្រូវការបច្ចេកទេស GPS ការបញ្ចូលទិន្នន័យគូសដោយដៃទៅជាឌីជីថល ដែលត្រូវបានគាំទ្រផ្នែកបច្ចេកទេសដោយមន្ត្រីជំនាញ និងទទួលស្គាល់ពីអាជ្ញាធរពាក់ព័ន្ធ។ ដីស្នើសុំចុះបញ្ជីកម្មសិទ្ធិសមូហភាពស្ថិតក្នុងតំបន់មានមីនមិនទាន់បានដោះ ត្រួតស៊ីគ្នាជាមួយដីក្រុមហ៊ុន ជាន់តំបន់ការពារធម្មជាតិ/ច្រករបៀងជីវចម្រុះ ឬជាន់ដីព្រៃបម្រុងទុកអចិន្ត្រៃយ៍របស់រដ្ឋជាដើម ដែលពិបាកក្នុងការស្វែងរកកិច្ចព្រមព្រៀងពីភាគីក្រុមហ៊ុន ក្រសួងបរិស្ថាន ឬ ក្រសួងកសិកម្ម រុក្ខាប្រមាញ់

និងនេសាទ ដើម្បីរាជរដ្ឋាភិបាលអាចធ្វើអនុប្រយោគ និងប្រគល់ជូនសហគមន៍គ្រប់គ្រងជាសមូហភាពបាន។ កត្តារាំងស្ទះមួយទៀត សហគមន៍ស្នើសុំដីចំនួន៥ប្រភេទ ដូចដែលមានចែងក្នុងអនុក្រឹត្យលេខ៨៣ និងស្របតាមការទទួលស្គាល់សិទ្ធិប្រើប្រាស់ និងអាស្រ័យផលរបស់ជនជាតិដើមភាគតិច ដូចមានចែងនៅក្នុងច្បាប់ភូមិបាលឆ្នាំ២០០១ ប៉ុន្តែពួកគាត់មិនមានដីជាក់ស្តែងគ្រប់ចំនួនទាំង៥ប្រភេទទេ។ កត្តាទាំងអស់នេះបានបង្កឱ្យដំណើរការចុះបញ្ជីដីសមូហភាពមានភាពយឺតយ៉ាវ និងមិនទាន់ឆ្លើយតបពេញលេញចំពោះការប្តេជ្ញាចិត្តរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ព្រមទាំងតម្រូវការរបស់សហគមន៍ ដែលនាំឱ្យសមាជិកមួយចំនួនមានចិត្តស្ទាក់ស្ទើរ ផ្លាស់ប្តូរចិត្តចង់ដកខ្លួនចេញពីសមាជិកសហគមន៍ជនជាតិដើមភាគតិច នៅពេលកំពុងដំណើរការចុះបញ្ជីដីសមូហភាព ខណៈមានចលនាបន្តុចបង្អាក់ ផ្សព្វផ្សាយ និងលើកទឹកចិត្តពីបុគ្គលមួយចំនួនឱ្យពួកគាត់ទទួលយកដីកម្មសិទ្ធិឯកជន ដែលអាចលក់ ដូរ ឬ បញ្ចាំបានដោយសេរី។ ចលនាចូលរុករានទន្ទ្រានកាន់កាប់ដីសាធារណៈរបស់រដ្ឋ ដែលស្ថិតក្នុងតំបន់ដីសហគមន៍ជនជាតិដើមភាគតិច ធ្វើជាកម្មសិទ្ធិ និងលក់ដូរ និងបញ្ជោជម្លោះដីធ្លីនៅក្នុងសហគមន៍ ដោយសារការទិញលក់ដីមិនស្របច្បាប់ ដែលមានការចូលរួមពីអាជ្ញាធរមូលដ្ឋានចុះហត្ថលេខាលើឯកសារពាក់ព័ន្ធ ក៏ជាមូលហេតុចម្បងមួយដែលនាំឱ្យដំណើការចុះបញ្ជីដីសមូហភាពជនជាតិដើមភាគតិចយឺតយូរដែរ។ ការទន្ទ្រានកាន់កាប់ដីនៅតំបន់ការពារ ដីព្រៃជំនឿ ព្រៃតំណម ព្រៃអារក្ស និងតំបន់កប់សពសហគមន៍ជនជាតិដើមភាគតិច មានកត្តាមួយចំនួនដែលជាឬសគល់នៃបញ្ហា រួមមាន កង្វះប្រសិទ្ធភាពអនុវត្តវិធានការការពារបណ្តោះអាសន្ន កង្វះប្រសិទ្ធភាពនៃយន្តការដោះស្រាយវិវាទ ការចូលរួមរបស់អាជ្ញាធរមូលដ្ឋានក្នុងការបញ្ជាក់លើឯកសារលក់-ទិញដីខុសច្បាប់ ផ្តល់កម្មសិទ្ធិឱ្យបុគ្គលឯកជនក្នុងតំបន់ដីសហគមន៍ជនជាតិដើមភាគតិច និងការរំលោភយកដីជាកម្មវត្ថុនៃការចុះបញ្ជីដីកម្មសិទ្ធិសមូហភាពពីអ្នកមានលុយ និងអំណាច។ ជាក់ស្តែង សហគមន៍ដែលទទួលបានវិធានការការពារបណ្តោះអាសន្នហើយ នៅតែបន្តទទួលរងការរំលោភបំពានយកដីកាន់កាប់ជាកម្មសិទ្ធិឯកជន ឬកម្មសិទ្ធិរបស់ក្រុមហ៊ុន។ ឧទាហរណ៍ ទី១. សហគមន៍ជនជាតិដើមភាគតិចកួយស្ថិតក្នុងភូមិងន ឃុំងន ស្រុកសណ្តាន់ ខេត្តកំពង់ធំ កំពុងស្ថិតក្នុងដំណើរការចុះបញ្ជីដីសមូហភាពជនជាតិដើមភាគតិច ដែលមានការចូលរួមចំណែកសម្របសម្រួលរបស់អង្គការអភិវឌ្ឍន៍ និងភាពជាដៃគូរក្នុងសកម្មភាព (DPA) ក្រោមការគាំទ្របច្ចេកទេសពីមន្ទីរ សាលាខេត្តកំពង់ធំ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងមហាផ្ទៃ និងក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់។ ជាលទ្ធផល សហគមន៍នេះត្រូវបានទទួលស្គាល់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិចកួយនៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៦ ទទួលស្គាល់ការចុះបញ្ជីសហគមន៍ជានីតិបុគ្គលដោយក្រសួងមហាផ្ទៃនៅថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៧ មានសមាជិកសរុប៩០គ្រួសារ ស្មើនិងចំនួនមនុស្ស៣៥១នាក់ (ស្ត្រី១៦៨នាក់)។ សហគមន៍នេះត្រូវបានរៀបចំផែនទីបឋម និងដាក់ពាក្យស្នើសុំចុះបញ្ជីដីសហគមន៍ជនជាតិភាគតិចលើផ្ទៃដីសរុប៦០០.៥១ហិកតា នៅថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៨។ បច្ចុប្បន្ន ដំណើរការចុះបញ្ជីដីសហគមន៍ជនជាតិដើមកំពុងប្រឈមនឹងទំនាស់ដីធ្លីជាមួយក្រុមហ៊ុនសម្បត្តិផ្កាទីនៀម ទទួលបានសម្បទានដីសេដ្ឋកិច្ចទំហំ២៤៩៦ហិកតា ពីរាជរដ្ឋាភិបាលកម្ពុជា កាលពីថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១១។ ក្រុមហ៊ុនបានបោះបង្គោលព្រំដីជាន់លើដីសហគមន៍ សរុបចំនួន៥២៥ហិកតា ជាប្រភេទ

ដីព្រៃជំនឿ ដីព្រៃបញ្ចុះសព ដីដាំដុះជាក់ស្តែង និងដីបម្រុងទុកសម្រាប់ការដាំដុះវិលជុំ ដែលជាកម្មវត្ថុនៃការចុះបញ្ជី។ នៅខែឧសភា ឆ្នាំ២០២០ ឯកឧត្តមអភិបាលខេត្តកំពង់ធំ បានដាក់ចេញនូវវិធានការការពារបណ្តោះអាសន្ន។ ករណីនេះ សមាជិកគណៈកម្មការគ្រប់គ្រងសហគមន៍ជនជាតិដើមភាគតិច ស្នើសុំឱ្យរាជរដ្ឋាភិបាលមេត្តាកាត់ឆ្វៀលដីពីក្រុមហ៊ុន ប្រគល់ជូនប្រជាពលរដ្ឋវិញ និងបន្តពន្លឿនដំណើរការចុះបញ្ជីឱ្យទទួលបានប័ណ្ណកម្មសិទ្ធិឆាប់រហ័ស។ ទី២. សហគមន៍សមូហភាពជនជាតិដើមភាគតិចនៅភូមិចក់ចារ ឃុំឈូក ស្រុកកែសីមា ខេត្តមណ្ឌលគិរី បានដំណើរការចុះបញ្ជីដីសមូហភាពជនជាតិដើមភាគតិចទទួលបានជានីតិបុគ្គល (លក្ខន្តិកៈសហគមន៍ត្រូវបានទទួលស្គាល់ដោយក្រសួងមហាផ្ទៃ)។ បច្ចុប្បន្ន ដំណើរការចុះបញ្ជីដីសមូហភាពជនជាតិដើមភាគតិច កំពុងជួបឧបសគ្គ និងបញ្ហាទំនាស់ដីធ្លីជាមួយក្រុមហ៊ុន បិញហឿក ក្រចេះរ៉ាប់ប៊ី ១ ខមភើនី លីមីធីត (BENH HOEURK KRATIE RUBBER 1 COMPANY LIMITED) តាំងពីឆ្នាំ២០១២។ ផ្ទៃដីទំនាស់ជាមួយក្រុមហ៊ុនមានទំហំ១៥០០ហិកតា ជាប្រភេទដីចំការវិលជុំ នៅចំណុចស្រែត្រាវ អូរតាយ៉ង់ ត្រពាំងថ្ម និងត្រពាំងផ្តើស នៃភូមិចក់ចារ។ ក្រៅពីនោះ ក៏មានការចូលរុករានទន្ទ្រានយកដីអារក្ស និងដីព្រៃបម្រុងទុករបស់សហគមន៍ពីសំណាក់ប្រជាពលរដ្ឋខាងក្រៅសហគមន៍ យកធ្វើជាកម្មសិទ្ធិបុគ្គល។ យោងតាមព័ត៌មានករណីខាងលើ និងរបាយការណ៍ស្រាវជ្រាវមួយចំនួនផ្សេងទៀតបានបង្ហាញថា ការអនុវត្តវិធានការការពារបណ្តោះអាសន្ន និងយន្តការដោះស្រាយបណ្តឹងវិវាទដីធ្លី នៅមិនទាន់មានប្រសិទ្ធភាព និងទាន់ពេលវេលាជូនសហគមន៍ជនជាតិដើមភាគតិច ដែលសិទ្ធិកម្មសិទ្ធិទាំងនេះត្រូវបានទទួលស្គាល់ និងការពារដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ច្បាប់ភូមិបាលឆ្នាំ២០០១ និងអនុក្រឹត្យលេខ៨៣ស្តីពីនីតិវិធី និងដំណើរការចុះបញ្ជីដីសមូហភាព។

- **បញ្ហាខ្វះប្រសិទ្ធភាពនៃការអនុវត្តលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍ជនជាតិដើមភាគតិច** គណៈកម្មការសហគមន៍មិនទាន់មានសមត្ថភាពគ្រប់គ្រាន់ក្នុងការដឹកនាំ និងការគ្រប់គ្រង យល់មិនសូវច្បាស់អំពីដំណើរការ និងការប្រើប្រាស់ទម្រង់លិខិត ដែលមានកំណត់ក្នុងឯកសារទាំងពីរនេះ និងខ្វះការគាំទ្រពេញលេញក្នុងការពង្រឹងការអនុវត្តលក្ខន្តិកៈពីអ្នកពាក់ព័ន្ធពិសេសអាជ្ញាធរមូលដ្ឋាន និងមន្ត្រីជំនាញ។ កត្តានេះបង្កឱ្យមានផលប៉ះពាល់ដល់ដំណើរការល្អរបស់សហគមន៍ សមាជិកខ្លះស្នើសុំចាកចេញពីសហគមន៍ សមាជិកខ្លះលក់ដីសហគមន៍ទៅឱ្យអ្នកខាងក្រៅ សមាជិកខ្លះស្ទាក់ស្ទើរក្នុងការបន្តចូលរួមដំណើរការចុះបញ្ជីដីកម្មសិទ្ធិសមូហភាព។

- **បញ្ហាអាជ្ញាធរមូលដ្ឋានមួយចំនួនពន្យល់ និងលើកទឹកចិត្តឱ្យជនជាតិដើមភាគតិចយករបបកម្មសិទ្ធិដីឯកជន** ដោយសារអាជ្ញាធរខេត្តនៅមិនទាន់យល់បានស៊ីជម្រៅអំពីអនុក្រឹត្យលេខ៨៣ស្តីពីនីតិវិធីនៃការចុះបញ្ជី និងផលប្រយោជន៍នៃកម្មសិទ្ធិសមូហភាព ដូច្នេះអាជ្ញាធរផ្សព្វផ្សាយតែផលប្រយោជន៍កម្មសិទ្ធិឯកជន និងលើកទឹកចិត្តសមាជិកសហគមន៍ឱ្យយករបបកម្មសិទ្ធិឯកជន ដើម្បីងាយស្រួលលក់ដូរ ឬដាក់បញ្ចាំដើម្បីដោះទាល់ពេលមានជំងឺ ឬពង្រីកមុខរបរជាដើម។

## ២.៣ អនុសាសន៍ និងសំណូមពរ

- ក្រសួងអភិវឌ្ឍន៍ជនបទ និងមន្ទីរគួរពន្លឿនការទទួលស្គាល់ស្វ័យអត្តសញ្ញាណ ថែរក្សា និងចងក្រងវប្បធម៌ ប្រពៃណីជនជាតិដើមភាគតិចតាមរយៈសកម្មភាពជាយុទ្ធសាស្ត្រចំនួន៤សំខាន់ រួមមាន៖ ទី១. ពង្រឹងសហការជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គការដៃគូចុះផ្សព្វផ្សាយអំពីប្រយោជន៍នៃស្វ័យអត្តសញ្ញាណ និងសិទ្ធិជនជាតិដើមភាគតិច ដែលទទួលស្គាល់ដោយច្បាប់ និងគោលនយោបាយជាតិ និងលិខិតូបករណ៍អន្តរជាតិ[1] ផលប្រយោជន៍នៃកម្មសិទ្ធិសមូហភាព និងឯកជនជាមុន ដើម្បីឱ្យសហគមន៍ជនជាតិដើមភាគតិចធ្វើការសម្រេចចិត្តត្រឹមត្រូវ។ ទី២. ពង្រឹងកិច្ចសហការជាមួយក្រសួង និងមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ អាជ្ញាធរមូលដ្ឋាន និងអង្គការដៃគូធ្វើការសិក្សាស្រាវជ្រាវអត្តសញ្ញាណ វប្បធម៌ ប្រពៃណីជនជាតិដើមភាគតិច និងចងក្រងទុកជាឯកសារ។ ទី៣. សហការជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គការដៃគូរៀបចំសំណុំឯកសារ និងទទួលស្គាល់ស្វ័យអត្តសញ្ញាណជនជាតិដើមភាគតិច។ ទី៤. ធ្វើអន្តរាគមន៍ទប់ស្កាត់ និងថែរក្សាការពារដីព្រៃជំនឿ ព្រៃតំណម ដើម្បីកុំឱ្យមានការរំលោភបំពានតាមគ្រប់រូបភាព ពីព្រោះដីព្រៃទាំងនេះជាវប្បធម៌ប្រពៃណី និងជីវភាពរបស់ពួកគាត់។

- **រាជរដ្ឋាភិបាលកម្ពុជាគួរពន្លឿននីតិវិធីនៃការចុះបញ្ជីដីសមូហភាពជនជាតិដើមភាគតិច ដើម្បីធានាសុវត្ថិភាពដីធ្លីរបស់សហគមន៍ជនជាតិដើមភាគតិច។** ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ គប្បីពិនិត្យពិចារណាលើកិច្ចការ៨សំខាន់ រួមមាន៖ ទី១. បន្តផ្សព្វផ្សាយខ្លឹមសារច្បាប់ភូមិបាលឆ្នាំ២០០១ ចាប់ពីមាត្រា២៣ដល់២៨ ដោយផ្តោតលើសារប្រយោជន៍នៃរបបកម្មសិទ្ធិឯកជន និងសមូហភាពដល់អាជ្ញាធរមូលដ្ឋាន និងសហគមន៍ជនជាតិដើមភាគតិច។ ទី២. ពិនិត្យ និងកែសម្រួលដំណើរការនៃការកសាងផែនទីបឋមឱ្យមានលក្ខណៈសាមញ្ញ គឺគណៈកម្មការបណ្ដោះអាសន្នសហគមន៍ចាស់ទុំភូមិ និងចូលរួមដោយអាជ្ញាធរភូមិ-ឃុំធ្វើផែនទីក្បាលដីបឋម (sketch map) ដោយកំណត់ព្រំដីតាមទីតាំង តាមប្រភេទដី និងទំហំប្រហាក់ប្រហែល និងបញ្ជីសហគមន៍គ្រួសារ ដែលស្ថិតក្នុងក្បាលដីរួម (ក្រុមៗ) ដោយប្រើនិមិត្តសញ្ញា (ពណ៌) តាមប្រភេទដីផ្សេងៗពីគ្នា។ បន្ទាប់មកសមាជិកសហគមន៍ អាជ្ញាធរ ភូមិ ឃុំ ស្រុក មន្ទីរបរិស្ថាន ខណ្ឌរដ្ឋបាលព្រៃឈើ ចាស់ទុំ និងអង្គការគាំទ្រពិនិត្យប្រភេទដីដែលមានក្នុងផែនទីនោះ តើដីទាំងនោះអាចជាន់ជាមួយនឹងតំបន់ការពារ ឬព្រៃបម្រុងទុកអចិន្ត្រៃយ៍ដែរឬទេ។ ទី៣. កុំទាន់ផ្តើមអនុវត្តការចុះបញ្ជីដីជាប្រព័ន្ធនៅក្នុងតំបន់ជនជាតិដើមភាគតិច ដើម្បីជៀសវាងសមាជិកសហគមន៍ងាកមកទទួលយកកម្មសិទ្ធិឯកជនវិញ ដោយមិនយល់ច្បាស់ពីផលប្រយោជន៍ កម្មសិទ្ធិសមូហភាពជនជាតិដើមភាគតិច។ ទី៤. ទប់ស្កាត់មន្ត្រីខិលខូចមួយចំនួន ក្រុមឈ្មួញ និងប្រជាពលរដ្ឋពីខាងក្រៅដែលធ្វើសកម្មភាពជំរុញឱ្យសមាជិកសហគមន៍ជនជាតិដើមភាគតិចងាកមកយករបបកម្មសិទ្ធិឯកជន ដោយខ្វះព័ត៌មានពេលលេញ និងត្រឹមត្រូវក្នុងការសម្រេចចិត្ត។ ទី៥. បង្កើតយន្តការ និងគណៈកម្មការដោះស្រាយវិវាទដីសមូហភាពជនជាតិដើមភាគតិចដាច់ដោយឡែក។ ទី៦. វិភាជន៍ថវិកាគាំទ្រដំណើរការ

---

[1] សេចក្តីប្រកាសអង្គការសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើមភាគតិច អនុញ្ញារបស់អង្គការ ILO លេខ១៦៩ និងច្បាប់ជាតិដូចជា រដ្ឋធម្មនុញ្ញ ច្បាប់ភូមិបាល ច្បាប់ព្រៃឈើ ច្បាប់ស្តីពីតំបន់ការពារ និងគោលនយោបាយជាតិស្តីពីការអភិវឌ្ឍជនជាតិដើមភាគតិច គោលនយោបាយស្តីពីការចុះបញ្ជីដីសមូហភាពជនជាតិដើមភាគតិច និងអនុក្រឹត្យលេខ៨៣ ស្តីពីនីតិវិធី និងដំណើរការចុះបញ្ជីដីសមូហភាព។

ចុះបញ្ជីដី និងពង្រឹងសមត្ថភាពគណៈកម្មការសហគមន៍។ ទី៧. សម្របសម្រួលរៀបចំកិច្ចប្រជុំរវាងក្រសួងបរិស្ថាន និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីឱ្យយល់គ្នាលើការបកស្រាយច្បាប់ដែលពាក់ព័ន្ធនឹងជនជាតិដើមភាគតិច ដូចជាច្បាប់ភូមិបាល ឆ្នាំ២០០១ ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ច្បាប់បរិស្ថាន និងអនុក្រឹត្យលេខ៨៣ ។ល។ ដើម្បីដោះស្រាយបញ្ហាដីស្នើសុំចុះបញ្ជីកម្មសិទ្ធិសមូហភាពត្រួតស៊ីគ្នាជាមួយតំបន់ការពារ។ ទី៨. អាជ្ញាធរមូលដ្ឋាន និងមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ត្រូវពិនិត្យការកាន់កាប់ដីក្នុងតំបន់ចុះបញ្ជីដីសមូហភាពជនជាតិដើមភាគតិច ដើម្បីធានាថាមិនមានការចូលរុករានទន្ទ្រានកាន់កាប់ថ្មី ដោយផ្តោតលើចំនួនអ្នកកាន់កាប់ ប្រើប្រាស់ជាក់ស្តែង ព្រមទាំងទប់ស្កាត់រាល់ការទន្ទ្រានកាន់កាប់ថ្មី។

- **ការចេញ និងអនុវត្តវិធានការការពារបណ្តោះអាសន្នឱ្យមានប្រសិទ្ធភាពខ្ពស់ដើម្បីការពារដីធ្លី វប្បធម៌ ប្រពៃណីជនជាតិដើមភាគតិចៈ**
  - រាជរដ្ឋាភិបាលកម្ពុជាគួរកែសម្រួលអនុញ្ញាតឱ្យអភិបាលនៃគណៈអភិបាលខេត្តចេញវិធានការការពារបណ្តោះអាសន្នក្រោយពេលទទួលបានស្វ័យអត្តសញ្ញាណរហូតដល់ទទួលបានប័ណ្ណកម្មសិទ្ធិពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។
  - ពង្រឹងការអនុវត្តវិធានការការពារបណ្តោះអាសន្នឱ្យមានប្រសិទ្ធភាពខ្ពស់ តាមរយៈការផ្សព្វផ្សាយឱ្យបានទូលំទូលាយនូវវិធានការការពារបណ្តោះអាសន្នទៅអ្នកពាក់ព័ន្ធ និងដាក់ទោសទណ្ឌចំពោះអ្នករំលោភដីសហគមន៍ជនជាតិដើមភាគតិច និងធ្វើឱ្យរាំងស្ទះដល់ដំណើរការចុះបញ្ជីដីសមូហភាពជនជាតិដើមភាគតិច។ស្នើសុំក្រសួងមហាផ្ទៃ និងក្រសួងអភិវឌ្ឍន៍ជនបទសហការជាមួយមន្ទីរអភិវឌ្ឍន៍ជនបទ និងអាជ្ញាធរមូលដ្ឋានចុះផ្សព្វផ្សាយ និងពង្រឹងចំណេះដឹងគណៈកម្មការសហគមន៍ និងពង្រឹងការអនុវត្តលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងឱ្យមានប្រសិទ្ធភាពខ្ពស់រៀងរាល់៣ខែម្តង។ស្នើសុំឱ្យរាជរដ្ឋាភិបាលតាមរយៈក្រសួងមហាផ្ទៃ ជួយទប់ស្កាត់អាជ្ញាធរមូលដ្ឋាន និងឈ្មួញដែលបានផ្សព្វផ្សាយ និងជំរុញឱ្យសមាជិកសហគមន៍ជនជាតិដើមភាគតិចចុះបញ្ជីដីកម្មសិទ្ធិឯកជន។

# ៣. ប្រធានបទស្តីពីព្រៃឈើ និងធនធានធម្មជាតិ

## ៣.១ សមិទ្ធិផល

- រាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងបរិស្ថាន បានផ្តល់ថវិកាសម្រាប់សហគមន៍តំបន់ការពារធម្មជាតិចុះល្បាតព្រៃ ក្នុង១សហគមន៍ ១ពាន់ដុល្លារ (សហគមន៍ខ្លះបាន ៣,០០០,០០០ រៀល) ។
- រាជរដ្ឋាភិបាលកម្ពុជា បានបង្កើតសហគមន៍តំបន់ទេសចរណ៍ធម្មជាតិក្នុងតំបន់ព្រៃបម្រុងទុកនៃដីកម្មសិទ្ធិសមូហភាព។
- រាជរដ្ឋាភិបាលកម្ពុជា បានបង្កើតសហគមន៍នេសាទចំនួន៥១៦សហគមន៍។
- គណៈបញ្ជាការឯកភាពខេត្តកំពង់ឆ្នាំង បានដកហូតយកដីអ្នកចូលរុករានដីព្រៃខុសច្បាប់ក្នុងដីដែនជម្រកភ្នំឱរ៉ាល់ ប្រគល់ជូនសហគមន៍តំបន់ការពារធម្មជាតិភ្នំជើងលៀង ដោយមានការបោះបង្គោលព្រំច្បាស់លាស់ និងដាំកូនឈើឡើងវិញ (សហគមន៍ផ្សេងកំពុងបន្តដោះស្រាយ)។

- រាជរដ្ឋាភិបាលកម្ពុជា បានកំណត់ និងបែងចែកគ្រប់គ្រងតំបន់ជុំវិញបឹងទន្លេសាប តំបន់១ តំបន់២ និងតំបន់៣ និងបានបោះបង្គោលព្រំក្នុងតំបន់បី។
- រាជរដ្ឋាភិបាលកម្ពុជា បានដាក់គម្រោងឥណទានកាបូនព្រៃឈើលើពិភពលោកមុនគេនៅខេត្តឧត្តមានជ័យមាន ដែនជម្រកសត្វ ព្រៃសង្ឃរុក្ខវ័ន វ៉េដបូកកែវសីមា ព្រៃឡង់...។ល។
- មន្ទីរកសិកម្មខេត្តកំពង់ឆ្នាំង បានចេញដីកាដកហូតដីជាង១០៨៩.២៦ ហិកតា អោយសហគមន៍វិញ ឆ្នាំ២០២០។
- រាជរដ្ឋាភិបាលកម្ពុជា កំពុងបន្តធ្វើវិសោធនកម្មច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ និងច្បាប់ស្តីពីជលផល។
- រាជរដ្ឋាភិបាលកម្ពុជា បានផ្ទេរសិទ្ធិអំណាចគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិពីក្រសួងបរិស្ថាន មកឃុំ/សង្កាត់គ្រប់គ្រង។

## ៣.២ បញ្ហាប្រឈម

- កង្វះការវាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញតាមបទដ្ឋានបច្ចេកទេស និងគតិយុត្ត និងការពិគ្រោះយោបល់ពេញលេញជាមួយសហគមន៍មូលដ្ឋាន និងអ្នកពាក់ព័ន្ធផ្សេងទៀតឱ្យបានត្រឹមត្រូវ មុននឹងអនុវត្តគម្រោងសម្បទានដីសេដ្ឋកិច្ច សម្បទានរ៉ែ និងការសិក្សារុករករ៉ែនៅក្នុងតំបន់ការពារធនធានធម្មជាតិ ឬតំបន់សហគមន៍ព្រៃឈើ បានធ្វើអោយប៉ះពាល់ដល់ធនធានធម្មជាតិ ជីវចម្រុះ និងការបំពុលបរិស្ថាន។

- កិច្ចសហការរវាងមន្ត្រីឧទ្យានុរក្ស និងសមាជិកបណ្តាញសហគមន៍ព្រៃឡង់នៅមានកំរិត។ ជាក់ស្តែង នៅឆ្នាំ២០២០ មន្ត្រីឧទ្យានុរក្សតំបន់ព្រៃឡង់ បានរារាំង និងហាមឃាត់សមាជិកបណ្តាញសហគមន៍ព្រៃឡង់មិនអោយចុះល្បាតព្រៃឡង់ ក្នុងគោលបំណងចូលរួមចំណែកទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើនៅក្នុងតំបន់ព្រៃឡង់។

- បញ្ហាចាក់ដីលុបសមុទ្ររំលោភចូលដែនដីសហគមន៍នេសាទដែលបានចុះបញ្ជីជានីតិបុគ្គលស្របច្បាប់ និងកំពុងដំណើរការចុះបញ្ជី តាមនីតិវិធីៈ ការចាក់លុបសមុទ្រនេះបានធ្វើឱ្យប៉ះពាល់ដល់ការគ្រប់គ្រងសហគមន៍នេសាទ បាត់បង់ព្រៃកោងកាង ជម្រកត្រី បំផ្លាញជីវចម្រុះ និងប៉ះពាល់ដល់ជីវភាពប្រជាជនយ៉ាងធ្ងន់ធ្ងរ ដោយសារមុខរបររបស់ពួកគាត់ពឹងផ្អែកទៅលើការនេសាទ។ ជាក់ស្តែង ក្រុមហ៊ុន IGB មានផ្ទៃដីគម្រោងអភិវឌ្ឍន៍ទំហំ២០០ហិកតា បានចាក់ដីលុបចូលដែនសហគមន៍នេសាទកែបថ្មី ស្ថិតនៅភូមិកែបថ្មី ឃុំបឹងទូក ស្រុកទឹកឈូ ខេត្តកំពត។ ក្រុមហ៊ុន ប៉ាប៉ាផាត បានចាក់ដីលុបរាល់ថ្ងៃចូលដែនសហគមន៍នេសាទចង្ហោន ស្ថិតនៅភូមិបង្ហោន ឃុំព្រែកត្នោត ស្រុកទឹកឈូ ខេត្តកំពត។ ក្រុមហ៊ុន ជីងត័រ មានផ្ទៃដីគម្រោងអភិវឌ្ឍន៍សរុបទំហំ ៦៣២ហិកតា (១៩២ហិកតា នៅភូមិព្រែកត្នោត និង៤៤០ហិកតា នៅភូមិត្រពាំងរពៅ) ឃុំព្រែកត្នោត ស្រុកទឹកឈូ ខេត្តកំពត។ ក្រុមហ៊ុន អ៊ុំនី ឌីវេលឡុបមែន ខូអិលធីឌី មានផ្ទៃដីគម្រោងអភិវឌ្ឍន៍ទំហំ៣៩១០ ហិកតា បានប៉ះពាល់ ជាន់លើដែនដីសហគមន៍នេសាទចំនួន៤០០ហិកតា នៅភូមិកំពង់កែស ភូមិ

ត្រពាំងសង្កែ ឃុំត្រពាំងសង្កែ និងសហគមន៍កំពង់សាមគ្គី ភូមិកំពង់ត្នោត ឃុំកូនសត្វ ស្រុកទឹកឈូ ខេត្តកំពត និង សហគមន៍នេសាទអូរក្រសារ នៅភូមិអូរក្រសារ សង្កាត់អូរក្រសារ ក្រុងកែប ខេត្តកែប សហគមន៍នេសាទកំពង់ត្រឡាច សហគមន៍នេសាទភូមិថ្មី នៅសង្កាត់ព្រៃធំ ក្រុងកែប ខេត្តកែប។ ឧត្តមសេនីយ ហ៊ួ ហាប់ បានចាក់ដីលុបចូលដែនសហគមន៍នេសាទតំបន់ឆ្នេរសមុទ្រជ្រោយស្វាយមានទំហំប្រមាណ៣ហិកតា ស្ថិតនៅភូមិជ្រោយស្វាយលិច ឃុំជ្រោយស្វាយ ស្រុកស្រែអំបិល ខេត្តកោះកុង ។ ក្រុមហ៊ុនគ្រីស្តាល់ វីរាមបិច មានផ្ទៃដីគម្រោងអភិវឌ្ឍន៍ទំហំ៤៣ហិកតា បានប៉ះពាល់ នៅភូមិអុង ឃុំរាម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ។ ដីព្រៃកោងកាងចំណុចបឹងកង្កែប នៅភូមិអុង ឃុំរាម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ តំបន់នេះកាន់ដោយអ្នកមានតួនាទីជាឧកញ្ញាសំអាងមានលិខិតផ្ទេរសិទ្ធិ លិខិតបញ្ជាក់ និងប័ណ្ណកម្មសិទ្ធិ។ បុគ្គលឯកជនមួយចំនួនទៀតបានចាក់លុបដីសមុទ្រយកធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួននៅចំណុចពយកំពេញ ភូមិ១ សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ និងនៅចំណុចភូមិ២ ឃុំទំនុករលក ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ និងចំណុចឆ្នេរព្រែកត្រែង ភូមិ៤ ឃុំអូរត្រេះ ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ។

- ការបាត់បង់ព្រៃកោងកាងនៅតំបន់ឆ្នេរៈ ការបាត់បង់បណ្តាលមកពីការទន្ទ្រានកាន់កាប់ដើម្បីយកដីធ្វើការកម្មសិទ្ធិផ្ទាល់ខ្លួន ដើម្បីធ្វើកសិកម្ម និងការសាងសង់សំណង់អាណាធិបតេយ្យ បណ្តាលឱ្យប៉ះពាល់សហគមន៍ជំពូខ្មៅ ស្ថិតភូមិជំពូខ្មៅ ឃុំទួលទទឹង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ។ សហគមន៍ជ្រលង ស្ថិតនៅភូមិកំពង់ស្មាច់តូច ឃុំទឹកល្អក់ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ។ តំបន់ព្រៃកោងកាងស្ថិតនៅភូមិកោះឈ្មាំង ឃុំស្វាយទងខាងត្បូង ស្រុកកំពង់ត្រាច ខេត្តកំពត។ ការបាត់បង់ព្រៃលិចទឹកនៅតំបន់អភិរក្សទន្លេសាប និងមេគង្គ ការបាត់បង់នេះដោយសារសកម្មភាពកាប់ទន្ទ្រានយកដីព្រៃលិចទឹកធ្វើជាដីកសិកម្ម ធ្វើជាកម្មសិទ្ធិឯកជន ដែលបង្កឱ្យមានផលប៉ះពាល់ទីជម្រកត្រីជីវចម្រុះ និងជីវភាពរស់នៅរបស់សហគមន៍មូលដ្ឋាន។

- **បញ្ហាសហគមន៍ព្រៃឈើមានពីរសំខាន់គឺ** ទី១. ដំណើរការចុះបញ្ជីមានលក្ខណៈស្មុគស្មាញ និងប្រើពេលវេលាយូរ ដោយសារការកំណត់ព្រំប្រទល់ព្រៃសហគមន៍មិនមានភាពច្បាស់លាស់ទាំងផែនទី និងបង្គោលព្រំ ខ្វះការចូលរួម និងដឹងឮជាសាធារណៈ មន្ត្រីអនុវត្តការងារមានជំហរមិនច្បាស់លាស់ និងខ្វះធនធានសម្រាប់អនុវត្តផែនការសកម្មភាព មានទំនាស់ផលប្រយោជន៍បុគ្គលទាំងខាងក្នុង និងខាងក្រៅសហគមន៍។ ទី២. កង្វះការគាំទ្រ និងការចូលរួមពេញលេញពីប្រជាពលរដ្ឋ អាជ្ញាធរមានសមត្ថកិច្ច អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធផ្សេងៗទៀត លើការងារគ្រប់គ្រង និងលើកកម្ពស់ជីវភាពសហគមន៍មូលដ្ឋាន។ ជាក់ស្តែងបញ្ហាទាំងអស់នោះមានដូចជាៈ ការចូលរុករានទន្ទ្រានដីសហគមន៍ពីសំណាក់អ្នកមានអំណាច ប្រជាពលរដ្ឋខាងក្រៅ និងក្នុងមូលដ្ឋាន។ ការប្រព្រឹត្តបទល្មើសព្រៃឈើដោយសារកង្វះខាតថវិកា និងមធ្យោបាយក្នុងសកម្មភាពល្បាត និងបញ្ហានិទណ្ឌភាព។ ការរំលាយសហគមន៍ព្រៃឈើដោយខ្លួនឯង ដោយសារកត្តាជីវភាពក្រីក្រគ្មានចំណូល មានតម្រូវការដី និងអស់ជំនឿចិត្តក្នុងការចុះបញ្ជី។ ពុំទាន់មានការទទួលស្គាល់ភាពស្របច្បាប់ និងការគាំទ្រលើកកម្ពស់បណ្តាញសហគមន៍ព្រៃឈើ ដើម្បីពង្រឹងសមត្ថភាព ការ

សម្របសម្រួលចែករំលែកព័ត៌មាន រៀបចំផែនការគ្រប់គ្រង ចងក្រងព័ត៌មាន និងការចូលរួមពិភាក្សាជាមួយអ្នកពាក់ព័ន្ធ។ សហគមន៍ព្រៃឈើខ្វះលទ្ធភាពក្នុងការបង្កើតឱ្យមានគម្រោងអេកូទេសចរណ៍ ដើម្បីបណ្តុះសេចក្តីស្រឡាញ់ព្រៃឈើ និងលើកកម្ពស់ជីវភាពសហគមន៍មូលដ្ឋាន។ **ចំណែកសហគមន៍តំបន់ការពារធម្មជាតិ** ក៏ជួបបញ្ហាផ្នែកគ្រប់គ្រង ឬអភិបាលកិច្ចដូចសហគមន៍ព្រៃឈើដែរ ប៉ុន្តែដំណើរការចុះបញ្ជីដីសហគមន៍តំបន់ការពារធម្មជាតិមានលក្ខណៈល្អប្រសើរជាងដំណើរការចុះបញ្ជីសហគមន៍ព្រៃឈើ។

- បទល្មើសជួញដូរឈើខុសច្បាស់នៅតែបន្តកើតមាន ដោយសារសមត្ថភាពរបស់មន្ត្រីមានសមត្ថកិច្ច ធនធាន និងបច្ចេកទេស នៅមានកម្រិត។ ទោះជាយ៉ាងនេះក្តី ការអនុវត្តច្បាប់ប្រឆាំងនឹងបទល្មើស និងការគ្រប់គ្រងបទល្មើសទទួលបានលទ្ធផលល្អប្រសើរជាង បើប្រៀបធៀបទៅនឹងឆ្នាំមុនៗ។

- បញ្ហាចន្លោះប្រហោងរបស់ច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីជលផល និងច្បាប់ស្តីពីតំបន់ការពារធម្មជាតិ និងការផ្អាកដំណើរការរៀបចំអនុម័តសេចក្តីព្រាងក្រមបរិស្ថាន។

## ៣.៣ សំណូមពរ និងអនុសាសន៍

- ពង្រឹងគុណភាពនៃរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម (EIA) ស្របតាមបទដ្ឋានបច្ចេកទេស និងបទដ្ឋានគតិយុត្តការផ្សព្វផ្សាយ និងការពិគ្រោះយោបល់ឱ្យបានគ្រប់ជ្រុងជ្រោយ ទូលំទូលាយជាមួយសហគមន៍ និងអ្នកពាក់ព័ន្ធសំខាន់ៗផ្សេងទៀត ស្របតាមគោលការណ៍ ស្តីពីការព្រមព្រៀងជាមុនដោយសេរី និងមានព័ត៌មានគ្រប់គ្រាន់ (FPIC)។ ពង្រឹងការតាមដានការអនុវត្តទៅតាមអនុសាសន៍ក្នុងរបាយការណ៍ EIA ចំពោះគម្រោងដែលបានអនុម័តរួច។ រាល់គម្រោងអភិវឌ្ឍន៍ទាំងឡាយណាដែលរកឃើញថា មានផលប៉ះពាល់ធ្ងន់ធ្ងរដល់សង្គម និងបរិស្ថាន ត្រូវបញ្ឈប់ការអនុវត្តគម្រោងអភិវឌ្ឍន៍ និងត្រូវមានវិធានទណ្ឌកម្ម។

- ក្រសួងបរិស្ថានគួរពិនិត្យលទ្ធភាព ផ្តល់កិច្ចសហការល្អ និងគាំទ្រសមាជិកបណ្តាញសហគមន៍ព្រៃឡង់ ដើម្បីអភិបាលកិច្ចព្រៃឡង់ឱ្យកាន់តែមានប្រសិទ្ធភាព និងសម្រេចបានតាមគោលបំណង និងផែនការយុទ្ធសាស្ត្រព្រៃឈើជាតិ។

- រាជរដ្ឋាភិបាលកម្ពុជា គួរពិនិត្យមើលឡើងវិញនូវរាល់ដំណើរការនៃការផ្តល់សម្បទានដី សម្រាប់អភិវឌ្ឍន៍គម្រោងតំបន់សេដ្ឋកិច្ចពិសេស និងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម (EIA) ពេញលេញប្រកបដោយបរិយាបន្ន ដើម្បីធានានូវគុណភាព និងការចូលរួមពិគ្រោះយោបល់ជាសាធារណៈ។ ក្នុងករណីលទ្ធផលនៃរបាយការណ៍ EIA រកឃើញថា តម្លៃសេដ្ឋកិច្ចនៃការអភិរក្សធំជាងតម្លៃសេដ្ឋកិច្ចនៃការអភិវឌ្ឍ នោះគម្រោងអភិវឌ្ឍន៍នេះត្រូវលុបចោល ដើម្បីទុកអភិរក្ស ផ្ទុយទៅវិញ បើតម្លៃសេដ្ឋកិច្ចនៃការអភិវឌ្ឍធំជាងតម្លៃសេដ្ឋកិច្ចនៃការអភិរក្ស អាចផ្តល់សិទ្ធិសម្បទានដើម្បីធ្វើការអភិវឌ្ឍបាន ប៉ុន្តែក្រុមហ៊ុនត្រូវមានការទទួលខុសត្រូវផ្នែកសង្គម និងបរិស្ថាន រួមមាន ការដោះ

ស្រាយផលប៉ះពាល់សំណាងដីធ្លីរបស់ប្រជាពលរដ្ឋ សហគមន៍នេសាទ សំណងលើមុខរបរដែលប្រជាពលរដ្ឋបាត់បង់ និងសំណងតម្លៃសេដ្ឋកិច្ច។ ជាមួយគ្នានេះ ក្រុមហ៊ុនត្រូវជួយផ្តល់សមត្ថភាពជំនាញដល់ប្រជាពលរដ្ឋមូលដ្ឋាន ដើម្បីទទួលបានឱកាសការងារពីគម្រោង។ ដើម្បីធានានូវនិរន្តភាពបរិស្ថាន ក្រុមហ៊ុនត្រូវអនុវត្តវិធានការកាត់បន្ថយ ផលប៉ះពាល់ឱ្យបានជាអតិបរិមា និងបង្កើតឬស្តារតំបន់អេកូជីវចម្រុះណាមួយជាតម្លៃតបស្នង។

- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គួរសហការជាមួយនឹងក្រសួង អាជ្ញាធរមូលដ្ឋាន អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធផ្សេងទៀត ដើម្បីធ្វើការទប់ស្កាត់ និងបង្ក្រាបបទល្មើសកាប់ព្រៃកោងកាង ព្រៃលិចទឹក រុករានដីរដ្ឋខុសច្បាប់យកមកធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួនតាមរយៈវិធានការ២សំខាន់ ៖ ទី១. វិធានការបង្ការ ពោលគឺ ការអប់រំផ្សព្វផ្សាយពន្យល់ប្រជាពលរដ្ឋបណ្តុះសេចក្តីស្រឡាញ់ធនធានធម្មជាតិ និងជីវចម្រុះ និងចូលរួមយ៉ាងសកម្មក្នុងកិច្ចការការពារអភិរក្សព្រៃកោងកាង។ ទី២. វិធានការតទល់ អាជ្ញាធរមានសមត្ថកិច្ច រួមមានគណៈកម្មការគ្រប់គ្រងដីរដ្ឋថ្នាក់ជាតិ និងក្រោមជាតិ នគរបាលយុត្តិធម៌ តុលាការគ្រប់លំដាប់ថ្នាក់ គួរចាត់វិធានការតទល់ប្រឆាំងនឹងបទល្មើសខាងលើឱ្យបានម៉ឺងមាត់ដោយមានតម្លាភាព គ្មានមនោសញ្ចេតនា ឬនិទណ្ឌភាពចំពោះបុគ្គលណាមួយឡើយ។

- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាន គួរពិនិត្យកែសម្រួលនីតិវិធីនៃដំណើរការចុះបញ្ជីសហគមន៍ព្រៃឈើ និងសហគមន៍តំបន់ការពារធម្មជាតិអោយមានភាពសាមញ្ញ ងាយស្រួល និងធ្វើប្រតិភូកម្មមុខងារ ក្នុងការចុះបញ្ជីទទួលស្គាល់សហគមន៍ទាំងពីរទៅថ្នាក់ក្រោមជាតិ (ថ្នាក់ខេត្ត)។ រាជរដ្ឋាភិបាលគួរតែវិភាជន៍ថវិកាថ្នាក់ជាតិទៅក្នុងផែនការវិនិយោគថ្នាក់ក្រោមជាតិ ដើម្បីឱ្យមុខងារចុះបញ្ជី ទទួលស្គាល់ និងការគ្រប់គ្រងធនធានធម្មជាតិឱ្យមានប្រសិទ្ធភាព។ ដំណើរការរៀបចំបង្កើត ចុះបញ្ជី គ្រប់គ្រងសហគមន៍គួរបើកឱ្យមានការចូលរួមពេញលេញពីសហគមន៍មូលដ្ឋាន និងអង្គការសង្គមស៊ីវិល ក្នុងភាពជាដៃគូជាមួយអាជ្ញាធរពាក់ព័ន្ធ ដើម្បីប្រសិទ្ធភាពអភិបាលកិច្ចធនធានធម្មជាតិ។ ដើម្បីធានាប្រសិទ្ធភាពការងារអភិបាលកិច្ចធនធានធម្មជាតិ ក្រសួងជំនាញគួរសហការជាមួយដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធផ្សេងទៀត ដើម្បីពង្រឹងសមត្ថភាពអាជ្ញាធរថ្នាក់ក្រោមជាតិ និងសហគមន៍។ រាជរដ្ឋាភិបាលគួរគាំទ្រ និងទទួលស្គាល់បណ្តាញសហគមន៍ព្រៃឈើ ដើម្បីពង្រឹងសមត្ថភាព ការសម្របសម្រួលចែករំលែកព័ត៌មាន រៀបចំផែនការគ្រប់គ្រង ចងក្រងព័ត៌មាន និងការចូលរួមពិភាក្សាជាមួយអ្នកពាក់ព័ន្ធ។ រាជរដ្ឋាភិបាលគួរបង្កើនការវិយោគលើការអភិវឌ្ឍអេកូទេសចរណ៍ក្នុងតំបន់សហគមន៍ព្រៃឈើ និងតំបន់ការពារធម្មជាតិ ដើម្បីបង្កើតមុខរបរសម្រាប់ប្រជាសហគមន៍ឱ្យពួកគាត់មានលទ្ធភាពក្នុងការចូលរួមគ្រប់គ្រង និងការពារធនធានធម្មជាតិឱ្យមានប្រសិទ្ធភាព។

- រាជរដ្ឋាភិបាលកម្ពុជាគួរពន្លឿនដំណើរការអនុម័ត ក្រមបរិស្ថាន សេចក្ដីព្រាងវិសោធនកម្មច្បាប់ព្រៃឈើ ច្បាប់តំបន់ការពារ និងច្បាប់ជលផល ដោយមានការចូលរួមពីក្រុមការងារអង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធសំខាន់ៗ ផ្សេងទៀតដើម្បីអភិបាលកិច្ចធនធានធម្មជាតិឱ្យមានប្រសិទ្ធភាព៕